លេខ១ ឆ្នាំ២០១៥

# ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## ដំណាក់កាលទី ១ ( ២០០៥ - ២០០៨ )

១. ភាពជឿទុកចិត្តបាននៃថវិកា៖ ពង្រឹងការគ្រប់គ្រងចំណូល និងការប្រមូលចំណូល, ការគ្រប់គ្រងសាច់ប្រាក់ និងគណនីទោលរតនាគារ

## ដំណាក់កាលទី ២ ( ២០០៩ - ២០១៥ )

២. គណនេយ្យភាពហិរញ្ញវត្ថុ៖ ចំណាត់ថ្នាក់ថវិកាថ្មី, ប្លង់គណនីថ្មី និងអង្គភាពថវិកា និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុ (FMIS)

## ដំណាក់កាលទី ៣ ( ២០១៦ - ២០២០ )

៣. ការផ្សារភ្ជាប់ថវិកា និងគោលនយោបាយ៖ ការកែទម្រង់ប្រព័ន្ធថវិកា, ផែនការយុទ្ធសាស្ត្រថវិកា (BSP), ថវិកាកម្មវិធី (BP) និងអង្គភាពថវិកា

## ដំណាក់កាលទី ៤ ( ២០២១ - ២០២៥ )

៤. គណនេយ្យភាពសមិទ្ធកម្ម៖ ការគ្រប់គ្រង និងវាយតម្លៃលទ្ធផល និងសមិទ្ធផល

# អារម្ភកថា

ក្នុងគោលបំណងបង្កើនការប្រាស្រ័យទាក់ទង បង្កើនការផ្សព្វផ្សាយ និងបង្កើនការយល់ដឹងនៅក្នុងនិងក្រៅរដ្ឋាភិបាល ពិសេសចំពោះសាធារណៈជនទូទៅ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានផ្តួចផ្តើមគំនិតបង្កើតព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះឡើង។

ព្រឹត្តិបត្រនេះ គឺជាស្នាដៃដ៏ថ្មីស្រឡាងមួយទៀតក្នុងចំណោមស្នាដៃនានា ដែលអគ្គលេខាធិការដ្ឋានបានដឹកនាំ រៀបចំ និងបោះពុម្ព ក្រោមការណែនាំ និងចង្អុលបង្ហាញដោយផ្ទាល់ពីឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្រ្តីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ យ៉ាងណាមិញ ទោះជាអគ្គលេខាធិការដ្ឋានបានខិតខំប្រឹងប្រែងប្រើប្រាស់តាមលទ្ធភាព និងធនធានជាក់ស្តែង តាមដែលអាចធ្វើទៅបានក៏ដោយ ក៏ផលិតផលដ៏ថ្មីស្រឡាងនេះ ពិតជាមិនអាចជៀសផុតពីកង្វះខាតមួយចំនួនបានឡើយ ទាំងផ្នែកគុណភាព និងសោភណ្ឌភាព ព្រោះម្យ៉ាង គឺជាការងារថ្មីសម្រាប់អគ្គលេខាធិការដ្ឋាន និងម្យ៉ាងទៀត អគ្គលេខាធិការដ្ឋានពុំទាន់មានធនធានមនុស្សគ្រប់គ្រាន់សម្រាប់ធ្វើការងារនេះ។ ដោយឡែក ក្នុងនាមជាសេនាធិការឱ្យរដ្ឋាភិបាលក្នុងការដឹកនាំការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ អគ្គលេខាធិការដ្ឋានអាចចាត់ទុកថា ផលិតផលថ្មីនៃព្រឹត្តិបត្រលេខដំបូងនេះជាព្រឹត្តិបត្រតែមួយគត់ដែលនឹងផ្តល់នូវប្រភពធនធានចំណេះដឹងដែលផ្តោតជាពិសេសទៅលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា បម្រើចំណីពុទ្ធិដល់សិស្ស និស្សិត បញ្ញវន្ត សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ ជាពិសេស មន្ត្រីរាជការគ្រប់ក្រសួង ស្ថាប័ន ដែលកំពុងអនុវត្តការងារកែទម្រង់នេះអនុវត្តទៅប្រកបដោយស័ក្តិសិទ្ធភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ហើយក៏សង្ឃឹមដែរថា ព្រឹត្តិបត្រនេះនឹងទទួលបានការគាំទ្រ និងការលើកទឹកចិត្ត ព្រមទាំងការកែលម្អពីសំណាក់មិត្តអ្នកអាន និងសាធារណជនពីគ្រប់ស្រទាប់មហាជន ធ្វើឱ្យព្រឹត្តិបត្រលេខក្រោយៗកាន់តែល្អប្រសើរជូនដល់មិត្តអ្នកអាន និងសាធារណជនបានថែមទៀត។

អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានជំនឿយ៉ាងមុតមាំថា ព្រឹត្តិបត្រនេះនឹងក្លាយជាឧបករណ៍ប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពក្នុងការបង្កើនការប្រាស្រ័យទាក់ទង ការផ្សព្វផ្សាយ និងការយល់ដឹងសម្រាប់មិត្តអ្នកអាន និងសាធារណជនគ្រប់ស្រទាប់សង្គម។ អគ្គលេខាធិការដ្ឋានសូមគោរពថ្លែងអំណរគុណចំពោះការណែនាំ និងចង្អុលបង្ហាញដោយផ្ទាល់ពីឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី ដែលពិតជាការរួមចំណែកមិនអាចខ្វះបានក្នុងការធ្វើឱ្យព្រឹត្តិបត្រនេះអាចប្រសូត្រចេញបាន៕

# មាតិកា


- អាណត្តិថ្មីមានអ្វីប្លែកនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ? ១៣
- វិធានការ ៦០ ថៃ.ដើម្បីបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព ដើម្បីប្រមូលចំណូលគយ ១៦
- វិធានការ១ខែ មាន២៨ ថ្ងៃនៃការបើកបៀវត្ស ១៨
- ពីលេខាធិការដ្ឋាន ទៅ អគ្គលេខាធិការដ្ឋានៈ តើមានអ្វីថ្មី ? ១៩
- ការកែទម្រង់ប្រព័ន្ធថវិកា គឺជាស្នូលនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ២០
- ក្រមនីយកម្មក្នុងវិស័យពន្ធដារ ២៣
- យុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈនៅកម្ពុជា ២៦
- ទិសដៅយុទ្ធសាស្ត្រការកែទម្រង់ប្រព័ន្ធថវិកា ២០១៣ - ២០២០ ២៧
- ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ៣០
- មាតិកាថវិកាថ្មី ៣២
- ថវិកាកម្មវិធី ៣៥
- ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុ (FMIS) ជាអ្វី ? ៣៦


# ព្រឹត្តការណ៍សំខាន់ៗ



ជំហានថ្មីលើវិថីនៃការកែទម្រង់ថវិកា
ទំព័រ ១

យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម៖ ស័ក្តិសិទ្ធភាព ប្រសិទ្ធភាព សុក្រឹតភាព និងតម្លាភាពនៃការប្រមូលចំណូល ទំព័រ ៤



សន្និសីទតំបន់អាស៊ីស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៖
មេរៀន - សង្ឃឹម និង ទឹកភ្នែក
ទំព័រ ៦



វេទិកាសាធារណៈស្តីអំពីច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥
ទំព័រ ៩

## ជំហានថ្មីលើវិថីនៃការកែទម្រង់ថវិកា

ស្ថិតក្នុងក្របខ័ណ្ឌកម្មវិធីនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការរៀបចំ និងការអនុវត្តថវិកានៅកម្ពុជាចាប់តាំងពីឆ្នាំ២០០៥ រហូតមក ត្រូវបាននិងកំពុងបន្តកែលម្អជារៀងរាល់ឆ្នាំក្នុងគោលដៅឆ្ពោះទៅរកការកែលម្អប្រព័ន្ធថវិកាជាបណ្តើរៗផង និងធានាបម្រើឱ្យបាននូវគោលនយោបាយតាមវិស័យរបស់ក្រសួងស្ថាប័នផង ជាពិសេស ចាប់តាំងពីការដាក់ឱ្យអនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនៅឆ្នាំ២០០៨ មកនៅពេលដែលផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធីត្រូវបានដាក់ឱ្យអនុវត្តជាលើកដំបូង។

ស្របតាម**ទស្សនាទានស្តីពីការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ២០១៣ - ២០២០** របស់រាជរដ្ឋាភិបាល ឆ្នាំ២០១៥ គឺជាជំហានថ្មីមួយទៀតលើវិថីនៃការកែទម្រង់ប្រព័ន្ធថវិកាដែលក្រសួងចំនួន១០ ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញសាកល្បង ហើយជាបណ្តើរៗពង្រីកទៅគ្រប់ក្រសួង ស្ថាប័ន ដើម្បីឈានទៅសម្រេចឱ្យបាននូវការកសាងប្រព័ន្ធថវិកាទំនើបមួយនៅកម្ពុជានៅឆ្នាំ២០២០ ដែលជាប្រព័ន្ធផ្អែកលើលទ្ធផល និងវិមជ្ឈការ។ ការរៀបចំ និងការអនុវត្តថវិកានឹងត្រូវបានកែលម្អមួយកម្រិតថែមទៀតតាមរយៈ (១)ការពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកានិងថវិកាកម្មវិធី (២) ការបន្តធានារក្សាឱ្យបាននូវភាពជឿទុកចិត្តបាននៃថវិកា (៣)សម្រេចឱ្យបានជាសារវន្តនូវគណនេយ្យភាពហិរញ្ញវត្ថុតាមរយៈការដាក់ឱ្យអនុវត្តប្លង់គណនីថ្មី មាតិកាថវិកាថ្មី កិច្ចប្រតិបត្តិការថ្មី និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ។

ដូច្នេះ ថវិកាឆ្នាំ២០១៥ មិនត្រឹមតែបានឆ្លុះបញ្ចាំងពីការកែទម្រង់ស៊ីជម្រៅផ្នែករដ្ឋបាលប៉ុណ្ណោះទេ តែថែមទាំងឆ្លុះបញ្ចាំងអំពីការកែទម្រង់ជាបច្ចេកទេសស៊ីជម្រៅនៃប្រព័ន្ធថវិកាថែមទៀតតាមរយៈ÷

(១)ការបង្កើនការរៀបចំថវិកាឱ្យកាន់តែផ្សារភ្ជាប់ទៅនឹងគោលនយោបាយ ធ្វើឱ្យការវិភាជថវិកាកាន់តែមានមូលដ្ឋានច្បាស់លាស់ និងវិភាជចំគោលដៅ ដើម្បីបង្កើនប្រសិទ្ធភាពវិភាជន៍ ព្រមទាំងបន្តពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ពិសេស កែលម្អការកំណត់គោលនយោបាយ ការរៀបចំសូចនាករ និងគោលដៅសម្រាប់វាស់វែងលទ្ធផល និងការប៉ាន់ស្មានតម្រូវការចំណាយរយៈពេលមធ្យមឱ្យកាន់តែសុក្រឹត ស្របតាមទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ២០១៣-២០២០ ដែលមានគោលដៅផ្លាស់ប្តូរជាបណ្តើរៗនូវប្រព័ន្ធថវិកាកម្ពុជាពីការផ្តោតលើធាតុចូលនិងមជ្ឈការ ទៅជាប្រព័ន្ធទំនើបមួយដែលផ្តោតលើធាតុចេញ(លទ្ធផល) និងវិមជ្ឈការ។ ជាក់ស្តែង ក្រសួងចំនួន១០ ត្រូវបានដាក់ឱ្យអនុវត្តសាកល្បងថវិកាកម្មវិធីពេញលេញចាប់ពីឆ្នាំ២០១៥ តទៅ ដែលរួមមានក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ ក្រសួងសាធារណៈការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

(២)ការពង្រឹងការអនុវត្តថវិកាឱ្យកាន់តែមានស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពតាមរយៈការកែលម្អក្របខ័ណ្ឌគតិយុត្ត នីតិវិធី និងកិច្ចប្រតិបត្តិការរដ្ឋបាល ជាពិសេសការកាត់បន្ថយនីតិវិធីធានាចំណាយ នីតិវិធីលទ្ធកម្មសាធារណៈ និងការទូទាត់។ ទន្ទឹមនឹងនេះ មាតិកាថវិកាថ្មី ប្លង់គណនេយ្យថ្មី និងការគ្រប់គ្រងហិរញ្ញវត្ថុដោយប្រព័ន្ធព័ត៌មានវិទ្យានឹងត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៥ នេះ ដែលការអនុវត្តថវិកានឹងមិនត្រឹមតែត្រូវបានបង្កើនស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាពប៉ុណ្ណោះទេ តែគណនេយ្យភាព និងតម្លាភាពហិរញ្ញវត្ថុក៏នឹងត្រូវបានបង្កើនថែមទៀត។

(៣) ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនឹងកាន់តែត្រូវបានពង្រឹង និងបង្កើនតាមរយៈការពង្រឹង និងបង្កើនការគោរពវិន័យថវិកា ការកាត់បន្ថយឱនភាពថវិកា ការកាត់បន្ថយហានិភ័យថវិកា និងការពង្រីកលំហថវិកាដោយការបង្កើនចំណូលតែមិនបង្កើតពន្ធថ្មី ឬ ដំឡើងអត្រាពន្ធ និងការរក្សាកំណើនចំណាយឱ្យទាបជាងកំណើនចំណូល ដើម្បីបង្កើនប្រាក់បញ្ញើរាជរដ្ឋាភិបាល។

(៤)បន្តអនុវត្តវិធានការកែទម្រង់កាន់តែស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ជាពិសេស ការបន្តជំរុញការងារអភិបាលកិច្ចល្អ និងការងារកែទម្រង់សំខាន់ៗឱ្យកាន់តែស៊ីជម្រៅដូចជា ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ការកែទម្រង់កងកម្លាំងប្រដាប់អាវុធ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ព្រមទាំងការអនុវត្តការងារដោយប្រកាន់ខ្ជាប់នូវអភិក្រម **ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល និងព្យាបាល**។

ជាក់ស្តែង **ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលនៅក្នុងអាណត្តិទី៥ ដែលបានគូសបញ្ជាក់នៅក្នុងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ ថវិកាឆ្នាំ២០១៥ បានផ្តល់អាទិភាពទៅលើ៖**

***(១) ការបង្កើនចំណាយបន្ទុកបុគ្គលិក*** ពិសេសសម្រាប់អ្នកមានបៀវត្សទាប ដើម្បីកាត់បន្ថយគម្លាត និងសម្រាប់គ្រូបង្រៀន និងគ្រូពេទ្យ ដើម្បីលើកទឹកចិត្ត និងលើកតម្កើងអាជីពគ្រូបង្រៀន និងគ្រូពេទ្យ ព្រមទាំងក្នុងគោលដៅរួមចំណែកបង្កើនគុណភាពសេវាអប់រំ និងសេវាសុខាភិបាល។ ជាក់ស្តែង ចំណាយលើបន្ទុកបុគ្គលិកត្រូវបានបង្កើន២៣,៤% ក្នុងពេលដែលចំណាយសរុបមានកំណើនត្រឹម១០,៨% លើច្បាប់ឆ្នាំ២០១៤។



***(២) ការបង្កើនចំណាយលើវិស័យសង្គមកិច្ច ពិសេស*** វិស័យអប់រំ។ ជាក់ស្តែង ចំណាយសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានបង្កើន១៨% ក្នុងពេលដែល

វិស័យសង្គមកិច្ចទាំងមូលមានកំណើនត្រឹម១៣,២% លើច្បាប់ឆ្នាំ២០១៤។

***(៣) បន្តបង្កើនចំណាយវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ*** ពិសេស ផ្លូវថ្នល់ ស្ពាន ប្រព័ន្ធធារាសាស្ត្រ និងបណ្តាញអគ្គិសនី ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងក្នុងការបន្តពង្រឹង និងពង្រីកសកម្មភាពសេដ្ឋកិច្ចក្នុងគោលដៅបន្តរក្សាកំណើនសេដ្ឋកិច្ចក្នុងកម្រិតប្រមាណ ៧% ប្រកបដោយចីរភាព និងកាត់បន្ថយអត្រាភាពក្រីក្រជាង១% ក្នុងមួយឆ្នាំ។

**ថវិកាឆ្នាំ២០១៥ នឹងត្រូវបានធ្វើហិរញ្ញប្បទានដោយចំណូលក្នុងប្រទេសនិងហិរញ្ញប្បទានក្រៅប្រទេសដូចតទៅ÷**

***(១)ចំណូលរដ្ឋសរុបក្នុងប្រទេសត្រូវបានគ្រោងក្នុងកំណើន១២,៣% ធៀបនឹងច្បាប់ឆ្នាំ២០១៤ ស្មើនឹង ១១ ៨១២ ៥៣០លានរៀល (១៥,៨៧% នៃផសស) ក្នុងនោះ ១១ ១៤៨ ២៣០លានរៀល (១៤,៩៨% នៃផសស) ជាចំណូលថ្នាក់ជាតិ និង៦៦៤ ៣០០ លានរៀល (០,៨៩% នៃផសស ជាចំណូលថ្នាក់ក្រោមជាតិ)***។ ចំណូលរដ្ឋសរុបនេះបានមកពី (១) ចំណូលចរន្តដែលរួមមានចំណូលសារពើពន្ធ (គយនិងរដ្ឋាករ ពន្ធដារ និងសារពើពន្ធផ្សេងទៀត) និងចំណូលមិនមែនសារពើពន្ធ (ការលក់ ឯកជនភាវូបនីយកម្ម ការជួល ការធ្វើសម្បទាន កម្រៃសេវា និងប្រាក់ចំណេញសហគ្រាសសាធារណៈ) និង (២) ចំណូលមូលធនដែលបានមកពីកម្រៃនៃការឱ្យគ្រឹះស្ថានសាធារណៈខ្ចីប្រាក់ សម្រាប់វិនិយោគ។ ចំណូលក្នុងប្រទេសត្រូវបានគ្រោងក្នុងកំណើន ១២,៣% ធៀបនឹងច្បាប់ឆ្នាំ២០១៤ ដែលក្នុងនោះចំណូលចរន្តត្រូវបានគ្រោងក្នុងកំណើន១៣,៤% ធៀបនឹងច្បាប់ឆ្នាំ២០១៤ ធ្វើឱ្យចំណូលចរន្តឡើងដល់១៤,៨% នៃផសស នៅឆ្នាំ២០១៥ និងចំណូលមូលធនត្រូវបានគ្រោងត្រឹម០,១៨% នៃផសស សម្រាប់ឆ្នាំ២០១៥ គឺថយចុះ៤២,៧% ធៀបនឹងច្បាប់ឆ្នាំ២០១៤ ដោយសារការជម្រះបំណុលជាមួយក្រុមហ៊ុនអគ្គិសនីកម្ពុជា និងការឧបត្ថម្ភធនរបស់រដ្ឋ។ ចំណូលសារពើពន្ធ ដែលជាចំណែកដ៏ធំសម្រាប់គាំទ្រដល់ការចំណាយ (៨៧% នៃចំណូលចរន្ត និង៨១% នៃចំណូលក្នុងស្រុក) ត្រូវបានគ្រោងក្នុងកំណើន១៤,៩% ស្មើនឹង១២,៨៣% នៃផសស (គយនិងរដ្ឋាករកើន១៣,៨% ស្មើ៧,០៨% នៃផសស, ពន្ធដារកើន១៧,៤% ស្មើ៥,៤១% នៃ ផសស, និងចំណូលសារពើពន្ធផ្សេងទៀតកើន២,៦%ស្មើ ០,៣៤% នៃផសស)។ រីឯចំណូលមិនមែនសារពើពន្ធ ដែលមានចំណែក១៣% នៃចំណូលចរន្ត និង១៣% នៃចំណូលក្នុងស្រុកត្រូវបានគ្រោងក្នុងកំណើន៤,៤% ធៀបនឹងច្បាប់ឆ្នាំ២០១៤ ស្មើនឹង១,៩៧% នៃផសស នៅឆ្នាំ២០១៥។

***(២) ចំណូលពីហិរញ្ញប្បទានក្រៅប្រទេសត្រូវបានគ្រោងក្នុងកំណើន៦,៦% ធៀបនឹងច្បាប់ឆ្នាំ ២០១៤ ស្មើនឹង៣ ៩៨៧ ០០០ លានរៀល (៥,៣៥% នៃផសស) ដែលក្នុងនោះ ៣០០ ០០០លានរៀល (០,៤០% នៃផសស) ក្រោមរូបភាពជាមូលនិធិទ្រទ្រង់ថវិកា និង ៣ ៦៨៧ ០០០លានរៀល (៤,៩៥% នៃផសស) ក្រោមរូបភាពជាកម្មវិធីនិងគម្រោង***។ ហិរញ្ញប្បទានក្រៅប្រទេសទាំងអស់ត្រូវបានទទួលក្នុងលក្ខណៈជាហិរញ្ញប្បទានឥត

សំណង់និងការខ្ចីសម្បទាន ហើយប្រើប្រាស់សម្រាប់តែគម្រោងវិនិយោគអាទិភាព សម្រាប់ការជំរុញកំណើនសេដ្ឋកិច្ច ពិសេស លើហេដ្ឋារចនាសម្ព័ន្ធរូបវន្តដូចជាផ្លូវថ្នល់ ស្ពាន ប្រព័ន្ធធារាសាស្ត្រ វារីអគ្គិសនី និងបណ្ដាញអគ្គិសនី។

## យុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម សក្ដិសិទ្ធភាព ប្រសិទ្ធភាព សុក្រឹតភាព និងតម្លាភាព នៃការប្រមូលចំណូល

កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៤ រាជរដ្ឋាភិបាលបានសម្រេចដាក់ឱ្យអនុវត្ត**យុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**។ ហេតុអ្វីរាជរដ្ឋាភិបាលត្រូវការយុទ្ធសាស្ត្រនេះ? តើយុទ្ធសាស្ត្រនេះនឹងត្រូវអនុវត្តយ៉ាងដូចម្ដេច? ហើយការអនុវត្តយុទ្ធសាស្ត្រនេះនឹងផ្ដល់អត្ថប្រយោជន៍អ្វីខ្លះ? សំណួរទាំងនេះគួរតែអាចឆ្លើយបាន មិនត្រឹមតែសម្រាប់ថ្នាក់ដឹកនាំនយោបាយនិងអ្នកបច្ចេកទេសនោះទេ ប៉ុន្តែគួរតែត្រូវបានយល់ដឹងឱ្យបានទូលំទូលាយ សម្រាប់អ្នកដែលមានកាតព្វកិច្ចបង់ពន្ធ ព្រោះចំណូលសាធារណៈទាំងក្នុងក្របខ័ណ្ឌមន្ត្រីរាជការ និងសាធារណៈជនទាំងអស់ ពិសេសរបស់រដ្ឋគឺបានមកពីការប្រមូលពីវិស័យឯកជន ឬពីអ្នកបង់ពន្ធ។

យោងតាមយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលមានគោលបំណង÷ (១) ឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ ពិសេស ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ និងសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ (២) ពង្រីកលំហថវិកាក្នុងគោលដៅពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ និង (៣) បង្កើនធនធាន សម្រាប់ធានាដល់តម្រូវការចាំបាច់ និងបន្ទាន់របស់រាជរដ្ឋាភិបាល។ ទន្ទឹមនឹងនេះ ក្នុងក្របខ័ណ្ឌកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិសេស សម្រាប់ជំហានទី៣ នៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ដើម្បីធានាលទ្ធភាពថវិកាសម្រាប់គាំទ្រគោលនយោបាយអាទិភាពតាមវិស័យតាមរយៈផែនការយុទ្ធសាស្ត្រថវិកា ដែលមានកំណត់គោលនយោបាយ និងកម្មវិធី សម្រាប់រយៈពេល៣ ឆ្នាំ ពិតជាតម្រូវឱ្យមានការបង្កើនសុក្រឹតភាពប៉ាន់ស្មាន និងស្ថិរភាពនៃការប្រមូលចំណូលសម្រាប់រយៈពេលមធ្យម។ ដើម្បីឆ្លើយតបទៅនឹងគោលបំណងនេះ យុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យមមានគោលដៅបង្កើនការប្រមូលចំណូលចរន្តក្នុងកម្រិត០,៥ ពិន្ទុភាគរយ គិតជាផលធៀបរវាងចំណូលចរន្តនិងផលិតផលក្នុងស្រុកសរុបជារៀងរាល់ឆ្នាំ ដែលនឹងត្រូវមានកំណើនពី១៥,២០% នៃផសស នៅឆ្នាំ២០១៤ ទៅដល់១៧,៣៦% នៃផសសនៅឆ្នាំ២០១៨។ ដើម្បីសម្រេចបានតាមគោលដៅខាងលើ យុទ្ធសាស្ត្រនេះនឹងផ្ដោតអាទិភាពទៅលើវិធានការពង្រឹងរដ្ឋបាលសារពើពន្ធ និងមិនមែនសារពើពន្ធព្រមទាំង លើកកម្ពស់វប្បធម៌បង់ពន្ធ និងការគោរពច្បាប់សំដៅប្រមូលចំណូលពន្ធគយ ពន្ធដារ និងចំណូលមិនមែនសារពើពន្ធប្រកបដោយប្រសិទ្ធភាព និងឱ្យអស់សក្ដានុពល។ ទន្ទឹមនឹងនេះ វិធានការកែទម្រង់មុតស្រួចក៏នឹងត្រូវបានអនុវត្តផងដែរ ដើម្បីកែលម្អរដ្ឋបាលសារពើពន្ធ និងលើកកម្ពស់អភិបាលកិច្ចសំដៅផ្ដល់ភាពងាយស្រួល និងការផ្ដល់សេវាប្រកបដោយប្រសិទ្ធភាពជូន

អ្នកបង់ពន្ធ ដែលនឹងរួមចំណែកផងដែរដល់ការកែលម្អបរិយាកាសវិនិយោគនិងការអភិវឌ្ឍវិស័យឯកជន ព្រមទាំងធានាបាននូវសមធម៌ និងយុត្តិធម៌ សម្រាប់ពលរដ្ឋគ្រប់រូប។ លើសពីនេះទៅទៀត យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមនេះ ក៏បានកំណត់យ៉ាងច្បាស់លាស់ផងដែរនូវវិធានការរយៈពេលខ្លី និងរយៈពេលមធ្យមដោយមានកំណត់ទាំងសកម្មភាពការងារជាក់ស្តែង ព្រមទាំងពេលវេលា និងសូចនាករសម្រាប់ការត្រួតពិនិត្យវឌ្ឍនភាពជាមួយនឹងការបញ្ជាក់យ៉ាងជាក់លាក់អំពីអង្គភាពដែលទទួលបន្ទុកអនុវត្ត។

យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើសសរស្តម្ភ៣ គឺ (១) ការពង្រឹងរដ្ឋបាលចំណូល ដែលរួមមានការពង្រឹងរដ្ឋបាលចំណូលនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ដែលក្នុងនោះរួមមានទាំងវិធានការរយៈពេលខ្លីនិងរយៈពេលមធ្យម (២) ការកែលម្អគោលនយោបាយចំណូល និងក្របខ័ណ្ឌស្ថាប័ន ដែលរួមមានការកែលម្អប្រព័ន្ធសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ និងការពង្រឹងយន្តការស្ថាប័ន ព្រមទាំងការកែលម្អគោលនយោបាយ និងក្របខ័ណ្ឌអនុវត្តចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធមួយចំនួនផងដែរ ព្រមទាំង (៣) ការពង្រឹងការត្រួតពិនិត្យនិងវាយតម្លៃតាមរយៈការបង្កើតគណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃ២ គឺគណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលសារពើពន្ធ និងគណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ ដែលគណៈកម្មាធិការទាំងពីរនេះនឹងធ្វើការត្រួតពិនិត្យ និងវាយតម្លៃទៅលើ (ក) ការអនុវត្តវិធានការដែលបានដាក់ចេញជាមួយនឹងការកំណត់សកម្មភាពការងារ ពេលវេលា ដែលត្រូវអនុវត្ត និងសូចនាករជាគុណភាពច្បាស់លាស់ និង (ខ) ការពិនិត្យទៅលើវឌ្ឍនភាពនៃសូចនាករជាបរិមាណ ដែលត្រូវបានកំណត់ជាកំណើនចំណូលជាមធ្យមប្រចាំឆ្នាំ និងបរិមាណចំណូលជាភាគរយនៃផលិតផលក្នុងស្រុកសរុប។

ដូច្នេះ យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ នេះ នឹងមិនត្រឹមតែធានាបានដល់ការពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូលទាំងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធប្រចាំឆ្នាំតាមច្បាប់កំណត់ ដែលនឹងរឹតតែធ្វើឱ្យភាពជឿទុកចិត្តបាននៃថវិកាកាន់តែត្រូវបានរក្សា និងធានាប៉ុណ្ណោះទេ តែថែមទាំងនឹងបង្កើនបាននូវស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃគោលនយោបាយចំណូល ព្រមទាំងបង្កើនបាននូវសុក្រឹតភាពនៃការព្យាករណ៍ចំណូលប្រចាំឆ្នាំ និងសម្រាប់រយៈពេលមធ្យម ដែលជាមូលដ្ឋានសម្រាប់ការបង្កើនស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាពនៃការរៀបចំ និងការអនុវត្តថវិកាថែមទៀតផង ជាពិសេស ក្នុងការបន្តពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងការអនុវត្តថវិកាកម្មវិធី៕

## សន្និសីទតំបន់អាស៊ីស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ÷

### មេរៀន - សង្ឃឹម និង ទឹកភ្នែក

កាលពីថ្ងៃទី២៥-២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ កន្លងទៅនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានសហការរួមគ្នារៀបចំសន្និសីទតំបន់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមប្រធានបទ "**មេរៀន-សង្ឃឹម និង ទឹកភ្នែក**" នៅរាជធានីភ្នំពេញ ដែលមានអ្នកចូលរួមប្រមាណ១៨០ នាក់ មកពី ១៥ប្រទេស នៅក្នុងតំបន់អាស៊ី រួមទាំងអ្នកជំនាញកម្រិតអន្តរជាតិមកពីស្ថាប័នអន្តរជាតិមួយចំនួនដូចជាធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោកជាដើម។ នេះជាសន្និសីទលើកទី៤ ដែលត្រូវបានរៀបចំឡើង ក្នុងនោះសន្និសីទតំបន់លើកទី១ បានប្រារព្ធធ្វើឡើងនៅក្នុងទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី នៅឆ្នាំ២០១០, លើកទី២ នៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េខាងត្បូង នៅឆ្នាំ២០១២ និងលើកទី៣ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន នៅឆ្នាំ ២០១៣។ សន្និសីទនេះ មានគោលបំណងផ្លាស់ប្តូរបទពិសោធន៍រវាងបណ្តាប្រទេសនៅក្នុងតំបន់ និងស្វែងយល់ពីបទពិសោធន៍នៃបណ្តាប្រទេសលើសកលលោកអំពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការធ្វើបទបង្ហាញ និងកិច្ចពិភាក្សាទៅលើប្រធានបទសំខាន់ចំនួន៦ គឺ (១) អភិក្រមជាជំហាននៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (២) ការគ្រប់គ្រងសមិទ្ធកម្ម និងការកែទម្រង់ការរៀបចំថវិកា (៣) ការធ្វើទំនើបកម្មការអនុវត្តថវិកា (៤) ឧបករណ៍វាយតម្លៃ និងការរួមចំណែករបស់វាក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (៥) ការកែទម្រង់សហគ្រាសសាធារណៈ និង (៦) ការគ្រប់-គ្រងដំណើរការវិសហមជ្ឈការហិរញ្ញវត្ថុ។

ជាលទ្ធផល អង្គសន្និសីទបានពិភាក្សាយ៉ាងផុស-ផុលស៊ីជម្រៅ និងប្រកបដោយផ្លែផ្កាតាមរយៈការធ្វើបទបង្ហាញ ការពិភាក្សាផ្លាស់ប្តូរមតិយោបល់ និងដកពិសោធន៍ពីគ្នាទៅវិញទៅមកលើប្រធានបទនីមួយៗ។ អភិក្រមជាជំហាន ដែលកម្ពុជាឈានមុខក្នុងការប្រើ-ប្រាស់ សម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានអង្គសន្និសីទទទួលស្គាល់ថា ជាអភិ-ក្រមដ៏សមស្រប និងអាចជាគំរូសម្រាប់យកទៅអនុវត្តនៅបណ្តាប្រទេសដទៃទៀត។ ទន្ទឹមនឹងនេះ អភិក្រមនាំមុខដោយមហិច្ឆតា ឬ ផ្តើមពីមូលដ្ឋានចាំបាច់មុន និងអភិក្រមនាំមុខដោយបច្ចេកវិទ្យាព័ត៌មានក៏ត្រូវបានលើកយកមកពិភាក្សាផងដែរ។

បច្ចុប្បន្ននេះ កម្ពុជាបានឈានមកដល់ជំហានទី ២ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ បន្ទាប់ពីជំហានទី ១ ភាពជឿទុកចិត្តបាននៃថវិកាត្រូវបានរក្សាជាសារវន្ត។ ដើម្បីត្រៀមខ្លួនទៅអនុវត្តជំហានទី៣ គឺការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ កម្ពុជាត្រូវការជាចាំបាច់នូវបទពិសោធន៍ និងមេរៀនមួយចំនួន ដែលក្នុងនោះអង្គសន្និសីទបានបង្ហាញអំពីបញ្ហា និងឧបសគ្គដែលប្រទេសនានាបានជួបប្រទះ ព្រមទាំងប្រសិទ្ធភាពនៃការកែទម្រង់ក្នុងការពង្រឹងដំណើរការថវិកាជាក់លាក់ប្រកបដោយប្រសិទ្ធភាព តាមរយៈបទបង្ហាញរបស់

តំណាងមកពីប្រទេសឥណ្ឌា និងម៉ាឡេស៊ីស្ដីពីមេរៀន និងឧបសគ្គ ក៏ដូចជាការសន្យាក្នុងការធ្វើថវិកាផ្អែកលើសមិទ្ធផល។ ជាមួយនឹងបទពិសោធន៍នេះ កម្ពុជាត្រូវខិតខំបន្តពង្រឹងការអនុវត្តថវិកាកម្មវិធី ដោយក្នុងនោះគោលបំណងគោលនយោបាយ និងកម្មវិធីយុទ្ធសាស្ត្រអាទិភាពនីមួយៗត្រូវតែមានការតាមដាន និងវាស់លទ្ធផលសម្រេចបានពីការអនុវត្តជាក់ស្ដែង តាមរយៈការកំណត់សូចនាករច្បាស់លាស់ និងអាចវាស់វែងបាន។ ជាមួយគ្នានេះដែរ ដើម្បីបន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកាឆ្ពោះទៅរកប្រព័ន្ធដ៏រឹងមាំ និងស្ថិរភាព និងក្នុងគោលដៅបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ កម្ពុជាខ្លួនឯងបាននិងកំពុងរៀបចំការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា (FMIS) និងត្រៀមដាក់ឱ្យដំណើរការនៅខែកក្កដា ឆ្នាំ២០១៥ ខាងមុខនេះ ក្នុងគោលបំណងបង្កើននូវស្វ័យប្រវត្តិកម្មផ្ទៃក្នុងរបស់រាជរដ្ឋាភិបាល។ ជាមួយនឹងការធ្វើបទបង្ហាញរបស់តំណាង IMF, ឥណ្ឌូនេស៊ី និងជប៉ុន ការធ្វើទំនើបកម្មការអនុវត្តថវិកានឹងមានបញ្ហាប្រឈម និងទាមទារចាំបាច់ឱ្យមានការពិនិត្យមើលឡើងវិញ ហើយលំនឹងដ៏ត្រឹមត្រូវមួយរវាងការត្រួតពិនិត្យលម្អិត និងភាពទន់ភ្លន់ ដើម្បីឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើប្រតិភូកម្មឱ្យបានច្រើន ក៏ត្រូវបានអង្គសន្និសីទរំលេចឱ្យឃើញផងដែរ។

ដោយឡែក ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពុំអាចធ្វើទៅបានដោយគ្មានឧបករណ៍វាយតម្លៃ ដើម្បីរួមចំណែកវាស់កម្រិតគណនេយ្យភាពហិរញ្ញវត្ថុ និងសូចនាករទាំងឡាយ។ ដូចនេះ ស្របពេលដែលរាជរដ្ឋាភិបាលកំពុងធ្វើការវាយតម្លៃលើចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) ឡើងវិញផងដែរ ក្នុងនោះតំណាងរបស់មូលនិធិរូបិយវត្ថុអន្តរជាតិនិងប្រទេសម៉ាល់ឌីវស៍បានធ្វើបទបង្ហាញស្ដីពីយន្តការសម្រាប់វាយតម្លៃសុខភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងគោលដៅ ដើម្បីរកឱ្យឃើញនូវផ្នែកដែលត្រូវផ្ដោតការយកចិត្តទុកដាក់នៅក្នុងដំណើរការនៃការកែទម្រង់ការគ្រប់គ្រងចំណាយសាធារណៈ នៅក្នុងបណ្ដាឆ្នាំទៅមុខ និងដើម្បីឱ្យកម្មវិធីកែទម្រង់ចុងក្រោយនៃប្រទេសកម្ពុជាទទួលបានអត្ថប្រយោជន៍ពីលំហាត់ក្នុងប្រទេស និងការរួមចំណែកពីក្រៅប្រទេស។

ពាក់ព័ន្ធនឹងវិស័យសហគ្រាសសាធារណៈ សន្និសីទបានបង្ហាញតាមរយៈធនាគារពិភពលោក ជប៉ុន និងឥណ្ឌាអំពីការចំណាយ និងហានិភ័យហិរញ្ញវត្ថុក្នុងកិច្ចដំណើរការសហគ្រាសសាធារណៈ ដែលជាផ្នែកមួយដ៏ធំរបស់រដ្ឋាភិបាលទូទៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ក្នុងនោះ កម្ពុជាបានទទួលនូវបទពិសោធន៍អំពីគោលនយោបាយល្អបំផុត ដើម្បីគ្រប់គ្រងសហគ្រាសសាធារណៈដែលចាំបាច់ត្រូវមានការកែលម្អ និងបង្កើនការយកចិត្តទុកដាក់ឱ្យបានខ្ពស់មួយកម្រិតថែមទៀត រួមទាំងការបង្កើតយន្តការតាមដាន និងវាយតម្លៃនៃលទ្ធផលដែលទទួលបានពីគ្រប់សហគ្រាសសាធារណៈទាំងអស់។ ប្រធានបទចុងក្រោយ ដែលអង្គសន្និសីទបានលើកយកមកពិភាក្សាតាមរយៈបទបង្ហាញរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងប្រទេសវៀតណាម គឺផ្ដោតទៅលើវិសហមជ្ឈការ និងវិមជ្ឈការ។ កិច្ចពិភាក្សានៅក្នុងប្រធានបទនេះបានបង្ហាញ

ថា វិមជ្ឈការអាចធ្វើឲ្យការផ្តល់សេវាសាធារណៈមានភាពកាន់តែល្អប្រសើរ។ លើសពីនេះទៅទៀត បណ្តាប្រទេសដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានប្រភពចំណូលផ្ទាល់បានទទួលអត្ថប្រយោជន៍ច្រើនជាងបណ្តាប្រទេសដែលរដ្ឋបាលថ្នាក់ក្រោមជាតិពឹងផ្អែកច្រើនតែទៅលើការឧបត្ថម្ភធនពីរដ្ឋបាលថ្នាក់ជាតិ។

បទពិសោធន៍នៅបណ្តាប្រទេសមួយចំនួន (ឥណ្ឌូនេស៊ី និងហ្វីលីពីន) ក៏បានបង្ហាញផងដែរថា ការកែទម្រង់វិមជ្ឈការអាចនាំឲ្យមាននិន្នាការនៃការបង្កើតតំបន់រដ្ឋបាលថ្មីដោយបំបែកចេញពីតំបន់រដ្ឋបាល ដែលមានស្រាប់ដែលអាចនាំឲ្យចំណាយរដ្ឋបាលមានការកើនឡើង។ ចំពោះកម្ពុជា វិសហមជ្ឈការ និងវិមជ្ឈការ បានចាប់ផ្តើមតាំងពីឆ្នាំ២០០២ តាមរយៈការបង្កើតឱ្យមានមូលនិធិឃុំ សង្កាត់ ដែលជាយន្តការផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវក្នុងការប្រើប្រាស់ធនធានហិរញ្ញវត្ថុក្នុងការបំពេញមុខងាររបស់រដ្ឋបាលឃុំ សង្កាត់។ ផ្អែកលើបទពិសោធន៍នេះ រាជរដ្ឋាភិបាលបានពង្រីកវិសាលភាពនៃវិសហមជ្ឈការ និងវិមជ្ឈការទៅដល់រដ្ឋបាលកម្រិតក្រុង ស្រុក ដោយបង្កើតឱ្យមានមូលនិធិក្រុង ស្រុក តាមរយៈការដាក់ឱ្យអនុវត្តច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨។ ទោះជាយ៉ាងណាបញ្ហាប្រឈមចំពោះមុខកម្ពុជា (១) ត្រូវរក្សាតុល្យភាពរវាងការផ្តល់សិទ្ធិអំណាចដល់ថ្នាក់ក្រោមជាតិ និងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ (២) ការផ្ទេរមុខងារពីរដ្ឋបាលកណ្តាលទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេស បញ្ហាសមត្ថភាពមន្ត្រីនៅថ្នាក់ក្រោមជាតិ (៣) ការកំណត់មូលដ្ឋាននៃការបែងចែកការប្រមូល និងការគ្រប់គ្រងប្រភពចំណូលរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ឆ្លងតាមរយៈការពិភាក្សាលើប្រធានបទទាំង៦ ក្នុងរយៈពេល២ ថ្ងៃនេះបានសម្រេចនូវផ្លែផ្កាធំៗរួមមានទាំងការផ្លាស់ប្តូរបទពិសោធន៍ពីបណ្តាប្រទេសជាច្រើនក្នុងតំបន់លើកិច្ចដំណើរការកែទម្រង់របស់ខ្លួន ការបង្កើត



*ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើជាអធិបតីភាពដ៏ខ្ពង់ខ្ពស់នៃសន្និសីទតំបន់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមប្រធានបទ **"មេរៀន - សង្ឃឹម និង ទឹកភ្នែក"**។*

នូវបណ្តាញទំនាក់ទំនងរវាងអ្នកជំនាញការជាន់ខ្ពស់ និងស្វែងយល់ពីគ្នាទៅវិញទៅមក។ ទន្ទឹមនឹងនេះ កម្ពុជាក៏មានឱកាសបង្ហាញពីកម្មវិធីកែទម្រង់របស់ខ្លួន ជាពិសេសអង្គសន្និសីទទាំងមូលបានទទួលស្គាល់ថា ការឈានមុខក្នុងការប្រើប្រាស់អភិក្រមជាជំហានក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាពិតជាអភិក្រមមួយដ៏សមស្រប និងត្រឹមត្រូវបំផុតសម្រាប់ប្រទេសនេះ។ ហើយមេរៀនទាំងឡាយនឹងក្លាយជាធាតុចូល សម្រាប់

កម្ពុជារៀបចំសម្រួចទិសដៅយុទ្ធសាស្ត្រ និងការរៀបចំផែនការសកម្មភាពកែទម្រង់នៅជំហានបន្ទាប់ ។ សន្និសីទនេះ គ្រាន់តែជាចំណុចចាប់ផ្តើមដំបូងប៉ុណ្ណោះ ព្រោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងបន្តរៀបចំកិច្ចប្រជុំពិភាក្សាបែបនេះជាច្រើនបន្តទៀតតាមផ្នែក និងប្រធានបទសំខាន់ៗ ក្នុងគោលដៅបង្កើនការផ្សព្វផ្សាយ បង្កើនការយល់ដឹង និងបង្កើនការចូលរួមពីគ្រប់មជ្ឈដ្ឋានទាំងនៅក្នុងរដ្ឋាភិបាល និងសង្គមទាំងមូល៕

## វេទិកាសាធារណៈអំពីច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥

នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំវេទិកាសាធារណៈស្តីពីច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ វេទិកា ដែលមានអ្នកចូលរួមចំនួនជាង១០០នាក់មានគោលបំណងបង្កើតវប្បធម៌សន្ទនាស្ថាបនាក្នុងស្រទាប់មហាជន បង្កើនការយល់ដឹង និងបង្កើតស័ក្តិសិទ្ធភាព ប្រសិទ្ធភាព និងតម្លាភាពនៃកិច្ចប្រតិបត្តិការការងាររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្នុងរយៈពេលជាង៣ ម៉ោង វេទិកាបានចាប់ផ្តើមពីការធ្វើបទអន្តរាគមន៍របស់រដ្ឋមន្ត្រី ជាមួយនឹងការធ្វើបទបង្ហាញរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយបន្ទាប់មកមានវេទិកាសំណួរចម្លើយសម្រាប់អ្នកចូលរួមទាំងអស់។ វេទិកានេះបានផ្តល់ឱ្យអ្នកសារព័ត៌មានផ្តិតយករូបភាពខ្លឹមសារ និងសកម្មភាពនៃវេទិកា និងដើម្បីធ្វើការផ្សព្វផ្សាយក្នុងគោលដៅបម្រើសាធារណជននូវព័ត៌មានដែលជាចំណីពុទ្ធិប្រកបដោយសច្ចៈភាព គុណភាព និងយុត្តិធម៌។

ជាកិច្ចចាប់ផ្តើម បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** បានផ្តល់បទអន្តរាគមន៍ជាពុទ្ធិដល់អង្គវេទិកាអំពីការរៀបចំច្បាប់ថវិកា ដោយបានផ្តោតលើប្រធានបទគន្លឹះ៥ រួមមាន÷ (១)តើគោលការណ៍នៃការរៀបចំថវិកានិងគោលនយោបាយនៃថវិកាឆ្នាំ២០១៥ ផ្តល់អាទិភាពលើអ្វី? (២) តើអាទិភាពទាំងនោះឆ្លើយតបទៅនឹងស្ថានភាពនយោបាយសេដ្ឋកិច្ច និងសេចក្តីត្រូវការរបស់សង្គមឬទេ? (៣) តើមានយុទ្ធសាស្ត្រ កម្មវិធី សកម្មភាពការងារ និងវិធានការសមស្របជាក់ស្តែង និងអាចជឿទុកចិត្តបានអ្វីខ្លះដែលជាអំណះអំណាង សម្រាប់ផ្តល់ក្តីសង្ឃឹមក្នុងការអនុវត្តគោលនយោបាយអាទិភាពទាំងនោះដែរឬទេ? (៤) តើថវិកាឆ្នាំ២០១៥ នឹងត្រូវធ្វើហិរញ្ញប្បទានយ៉ាងដូចម្តេចដើម្បីធានារក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ? និង (៥) តើមានការកែលម្អទៅលើចំណុចខ្វះខាត ដែលបានរកឃើញ និងមានគោលដៅបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពក្នុងការរៀបចំ និងការអនុវត្តថវិកាដែរឬទេ?

ឆ្លើយតបទៅនឹងសំណួរគន្លឹះទាំង៥ ឯកឧត្តមរដ្ឋមន្ត្រីបានផ្តើមអត្ថាធិប្បាយទៅលើទស្សនៈនៃការរៀបចំថវិកាដែលទស្សនៈនេះផ្តោតលើគោលការណ៍ និងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ក្នុងឆ្នាំនីមួយៗ ដែលត្រូវឈរលើការគោរពវិន័យថវិកា ការខិតខំពង្រឹងការប្រមូលចំណូលឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ការបង្កើនប្រសិទ្ធភាព និងបច្ចេកទេសប្រតិបត្តិការ

ចំណាយ ពិសេស ប្រសិទ្ធភាពនៃកិច្ចលទ្ធកម្មសាធារណៈ ការបង្កើនបៀវត្សតាមរយៈការកែទម្រង់រដ្ឋបាលសាធារណៈ និងការពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ។ ច្បាប់ថវិកាឆ្នាំ២០១៥ បានយកចិត្តទុកដាក់ខ្ពស់ទៅលើគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ពោលគឺកំណើនការងារ សមធម៌ និងការកាត់បន្ថយភាពក្រីក្រ និងការធានាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពនយោបាយ បន្តអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗ និងការបន្តជំរុញអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក៏ដូចជាធនធានមនុស្ស និងលើកកម្ពស់វិស័យសេវាសុខាភិបាល។

ឆ្លើយតបទៅនឹងគោលនយោបាយចំណាយជាអាទិភាព រាជរដ្ឋាភិបាលបានផ្តល់ការយកចិត្តទុកដាក់ទៅលើ (១) ការបង្កើតចំណាយបន្ទុកបុគ្គលិក ដែលមានកំណើន២៣,៤% (២) ការបង្កើនចំណាយលើវិស័យសង្គមកិច្ច ពិសេស សម្រាប់វិស័យអប់រំត្រូវបានបង្កើន ១៨% (៣) បង្កើនចំណាយវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ដែលមានទំហំ៧,៧៤% នៃផលិតផលសរុបក្នុងស្រុក។

ពាក់ព័ន្ធនឹងផ្នែកយុទ្ធសាស្ត្រ កម្មវិធី និងវិធានការ រាជរដ្ឋាភិបាល បានខិតខំជំរុញអនុវត្ត "ថវិកាកម្មវិធី" ដើម្បីធានាការផ្សារភ្ជាប់ការចំណាយថវិកាទៅនឹងគោលនយោបាយអាទិភាពនានា។ សម្រាប់ឆ្នាំ២០១៥ ក្រសួងចំនួន១០ ត្រូវអនុវត្តថវិកាកម្មវិធីដែលក្រសួងទាំងនោះសុទ្ធតែមានគោលនយោបាយ២ និងកម្មវិធី៥ ដើម្បីចូលរួមទ្រទ្រង់គោលនយោបាយរួមរបស់រាជរដ្ឋាភិបាល។

ឆ្លើយតបទៅនឹងសំណួរស្តីអំពីការធ្វើហិរញ្ញប្បទាន និងការធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលមានកាតព្វកិច្ចបន្តខិតខំពង្រឹងការប្រមូលចំណូលពីគ្រប់ទិសទី ក្នុងនោះ ប្រភពចំណូល២សំខាន់ៗត្រូវបានយកចិត្តទុកដាក់ខ្ពស់ (១) ចំណូលថវិកាក្នុងប្រទេសដែលគ្រោងមានកំណើន១២,៣% និងត្រូវបានពង្រឹងបន្ថែមទៀត តាមរយៈយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម និង (២)ចំណូលពីហិរញ្ញប្បទានក្រៅប្រទេស ដែលគ្រោងមានកំណើន៧,២% និងបង្កើតយុទ្ធសាស្ត្រប្រមូលចំណូលក្នុងប្រទេស។

ពាក់ព័ន្ធនឹងចំណុចកែលម្អ និងគោលដៅបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពក្នុងការរៀបចំ និងអនុវត្តថវិកា ឯកឧត្តមរដ្ឋមន្ត្រីបានលើកឡើងអំពី (១)វិធានការបង្កើនការរៀបចំថវិកាឱ្យផ្សារភ្ជាប់ទៅនឹងគោលនយោបាយតាមរយៈការធ្វើឱ្យការវិភាជថវិកាកាន់តែមានមូលដ្ឋានច្បាស់លាស់ និងកាន់តែចំគោលដៅ ដើម្បីបង្កើនប្រសិទ្ធភាពវិភាជន៍ (២) បង្កើនស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាពនៃការអនុវត្តថវិកា តាមរយៈការកែលម្អក្របខ័ណ្ឌគតិយុត្ត នីតិវិធី និងកិច្ចប្រតិបត្តិការរដ្ឋបាល នីតិវិធីលទ្ធកម្មសាធារណៈ និងនីតិវិធីនៃការបើកផ្តល់ទូទាត់ (៣) ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការកាត់បន្ថយនិន្នភាពទូទៅនៃថវិកា ការកាត់បន្ថយហានិភ័យថវិកា និងការពង្រីកលំហថវិកា រក្សាកំណើនចំណាយឱ្យទាបជាងកំណើនចំណូល និងធានាគ្រប់គ្រងបំណុលសាធារណៈប្រកបដោយស្ថិរភាព។

នៅកម្ពុជាឆ្នាំ២០២០ ស្របតាម "ទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា២០១៣-

២០២០” និងបន្ទាប់ទៀត ឈានទៅសម្រេចឱ្យបាននូវការកសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយមានកម្រិតស្តង់ដារអន្តរជាតិនៅឆ្នាំ២០២៥ ដែលជាចក្ខុវិស័យរយៈពេលវែងនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល។

បន្ទាប់ពីការធ្វើបទបង្ហាញ សំណួរមួយចំនួនត្រូវបានលើកឡើងពាក់ព័ន្ធនឹងការកែលម្អនីតិវិធីលទ្ធកម្មសាធារណៈ ផែនការចំណាយ និងប្រសិទ្ធភាពចំណាយ ការកែលម្អប្រព័ន្ធសារពើពន្ធដើម្បីលើកស្ទួយសហគ្រាសធុនតូច និងមធ្យម។ ឆ្លើយតបទៅនឹងនីតិវិធីលទ្ធកម្មសាធារណៈ ឯកឧត្តមរដ្ឋមន្ត្រីបានទទួលស្គាល់ពីភាពមិនប្រក្រតីមួយចំនួនដែលកើតមានកន្លងមក និងបានដាក់វិធានការក្នុងទិសដៅកែលម្អ និងពង្រឹងនីតិវិធីលទ្ធកម្មសាធារណៈ ដែលបទដ្ឋានគតិយុត្តមួយចំនួនទៀតកំពុងត្រូវបានបង្កើតបន្ថែមទៀត។ ទន្ទឹមនឹងនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវកិច្ចលទ្ធកម្មដោយខ្លួនឯងប្រកបដោយតម្លាភាព និងគណនេយ្យភាព។ ពាក់ព័ន្ធទៅនឹងផែនការចំណាយ និងប្រសិទ្ធភាពចំណាយ ឯកឧត្តមរដ្ឋមន្ត្រីបានបញ្ជាក់ថា ការរៀបចំថវិកានេះមិនត្រឹមតែផ្សារភ្ជាប់ទៅនឹងគោលនយោបាយអាទិភាពច្បាស់លាស់ និងឆ្លើយតបកាន់តែប្រសើរឡើងទៅនឹងស្ថានភាពនយោបាយ សេដ្ឋកិច្ច និងសេចក្តីត្រូវការប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងការអនុវត្តថវិកានេះក៏មានយុទ្ធសាស្ត្រ កម្មវិធី សកម្មភាពការងារ និងវិធានការជាក់ស្តែង និងអាចជឿទុកចិត្តបានថែមទៀត ដើម្បីសម្រេចបាននូវគោលនយោបាយអាទិភាពទាំងនោះ។ ក្នុងនោះ ឆ្នាំ២០១៥ គឺជាឆ្នាំដែលត្រូវឱ្យមានការជំរុញកំណើនការងារ សមធម៌ និងប្រសិទ្ធភាពស្របគ្នាទៅនឹងការអនុវត្តការកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាលឱ្យកាន់តែស៊ីជម្រៅ និងដែលមិនអាចមើលរំលងអំពីគុណភាពអប់រំ និងសុខាភិបាល និងហេដ្ឋារចនាសម្ព័ន្ធ។ ឆ្លើយតបទៅនឹងការកែលម្អប្រព័ន្ធសារពើពន្ធដើម្បីលើកស្ទួយសហគ្រាសធុនតូច និងមធ្យម (SMEs) បណ្ឌិតរដ្ឋមន្ត្រី បានបញ្ជាក់ថា រាជរដ្ឋាភិបាលបានជំរុញឱ្យមានការចុះបញ្ជីរបស់សហគ្រាសធុនតូច និងមធ្យមឱ្យបានគ្រប់ៗគ្នា ដើម្បីឱ្យសហគ្រាសទាំងនោះស្ថិតក្នុងប្រព័ន្ធតែមួយ និងមានកាតព្វកិច្ចបង់ពន្ធគ្រប់ៗគ្នា។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលនឹងរៀបចំបង្កើតឱ្យមានច្រកចេញចូលតែមួយ និងសម្រួលនីតិវិធីដល់សហគ្រាសធុនតូចនិងមធ្យមសម្រាប់ការចុះបញ្ជី និងការរៀបចំបែបបទផ្សេងៗ។ ដោយសារសហគ្រាសធុនតូច និងមធ្យមមានវិសាលភាពគ្របដណ្តប់ ៩០% នៃសេដ្ឋកិច្ចកម្ពុជា រាជរដ្ឋាភិបាលជំរុញឱ្យមានគោលនយោបាយលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម ដើម្បីជាកម្លាំងចលករដល់កំណើនសេដ្ឋកិច្ចជាតិ។

វេទិកាសាធារណៈនេះ ទទួលបានការគាំទ្រយ៉ាងពេញទំហឹង និងត្រូវបានចាត់ទុកថា ជាឱកាសដ៏កម្រពុំធ្លាប់មានពីមុនមក ហើយបានផ្តល់ជាពុទ្ធិដ៏មានតម្លៃដល់អ្នកចូលរួមឱ្យបានដឹង និងស្វែងយល់ឱ្យកាន់តែច្បាស់អំពីគោលនយោបាយថវិកា និងការប្រើប្រាស់ថវិកាឱ្យចំទិសដៅអាទិភាពរបស់រាជរដ្ឋាភិបាល។ មិនតែប៉ុណ្ណោះ វេទិកានេះបានស្រាយបំភ្លឺផ្លូវរាល់ចម្ងល់ និងបញ្ហាប្រឈមមួយចំនួនជូនដល់អ្នកចូលរួម ។

ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រីបានគូសបញ្ជាក់ថា ថវិកាឆ្នាំ២០១៥ បានបង្ហាញឱ្យឃើញយ៉ាងច្បាស់អំពីការបោះជំហានទៅមុខប្រកបដោយភាពជឿទុកចិត្តរបស់រាជរដ្ឋាភិបាលនៅលើវិថីនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយបានប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការបន្តរៀបចំវប្បធម៌សន្ទនាបែបនេះ ក្នុងទ្រង់ទ្រាយផ្សេងៗគ្នា ឱ្យបានកាន់តែច្រើនឡើងថែមទៀត ដើម្បីចែករំលែក និងធ្វើការផ្សព្វផ្សាយកាន់តែទូលំទូលាយអំពីផ្នែកផ្សេងៗទៀត ដើម្បីបំពេញសេចក្តីត្រូវការផ្នែកចំណេះដឹងរបស់មហាជន៕



*នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំវេទិកាសាធារណៈស្តីពីច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមបណ្ឌិត* ***អូន ព័ន្ធមុនីរ័ត្ន*** *រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។*

## អាណត្តិថ្មីមានអ្វីប្លែកនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ?

បង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការរបស់ខ្លួន គឺជាគោលដៅចម្បងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ដែលបានកំណត់នៅក្នុងយុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៣ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ជាពិសេស ក្នុងវិធានការកែទម្រង់ស៊ីជម្រៅនៅក្នុងអាណត្តិទី៥។ ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាននិងកំពុងបន្តធ្វើការកែទម្រង់យ៉ាងសកម្ម និងមុតស្រួច ពិសេសទាំងការកែទម្រង់ស្ថាប័ន ដែលរួមមានការកែលម្អរចនាសម្ព័ន្ធស្ថាប័ន ការកែលម្អការដឹកនាំ និងគ្រប់គ្រង ព្រមទាំងការកែលម្អកិច្ចប្រតិបត្តិការរដ្ឋបាល។ ទន្ទឹមនឹងនេះ ការកែទម្រង់ប្រព័ន្ធថវិកាដែលរួមមានការកែលម្អការរៀបចំថវិកា ការកែលម្អការអនុវត្តថវិកា ការកែលម្អគោលនយោបាយ និងការគ្រប់គ្រងចំណូល ព្រមទាំងការពង្រឹងសមត្ថភាព ការគ្រប់គ្រង និងការលើកទឹកចិត្តមន្ត្រី គឺជាការងារសំខាន់ និងចាំបាច់ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាអ្នកនាំមុខក្នុងក្របខ័ណ្ឌការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ការកែសម្រួលរចនាសម្ព័ន្ធស្ថាប័នដែលជាការងារដ៏លំបាកបំផុតនោះ គឺជាការងារទីមួយ ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចាប់ផ្តើមមុនគេជាមួយនឹងការកែសម្រួលឡើងវិញលើការដឹកនាំ ការគ្រប់គ្រង និងកិច្ចប្រតិបត្តិការរដ្ឋបាល ក្នុងគោលដៅបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពក្នុងកិច្ចប្រតិបត្តិការការងារ។***រចនាសម្ព័ន្ធក្រសួងត្រូវបានរៀបចំឡើងវិញ*** គឺពី២១ នាយកដ្ឋាន ទៅជា១២ អគ្គនាយកដ្ឋាន (អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ អគ្គនាយកដ្ឋានថវិកា អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ អគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងអគ្គាធិការដ្ឋាន) និងអគ្គលេខាធិការដ្ឋាន២ (អគ្គលេខាធិការដ្ឋានក្រសួង និងអគ្គលេខាធិការដ្ឋានកែទម្រង់)។***ការដឹកនាំ និងការគ្រប់គ្រងត្រូវបានកែសម្រួល*** ឱ្យស្របទៅនឹងរចនាសម្ព័ន្ធថ្មីផង និងដើម្បីបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពក្នុងការដឹកនាំ និងគ្រប់គ្រងផង និងជាពិសេស ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយ ២ របស់ក្រសួងគឺ (១) គ្រប់គ្រងសេដ្ឋកិច្ច និងអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ (២) គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋដែលគាំទ្រដោយកម្មវិធីចំនួន៥ គឺ (១) ការគ្រប់គ្រងសេដ្ឋកិច្ច (២) ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ (៣) ការកៀរគរចំណូលថវិកាជាតិ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (៤) ការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធនៃការគ្រប់គ្រងចំណាយសាធារណៈ និង (៥) ការផ្តល់សេវាគាំទ្រទូទៅ និងគណនេយ្យភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ទន្ទឹមនឹងនេះ ដើម្បីបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ ព្រមទាំងបង្កើនផលិតភាពការងាររបស់ក្រសួង ***កិច្ចប្រតិបត្តិការការងារ***

*រដ្ឋបាលមួយចំនួនត្រូវបានកែលម្អ* ពិសេស ក្នុងគោលដៅកាត់បន្ថយការិយាធិបតេយ្យ និងលុបបំបាត់អំពើពុករលួយ ដោយប្រតិបត្តិតាមអភិក្រម **ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល និងព្យាបាល** របស់សម្តេចតេជោនាយករដ្ឋមន្ត្រី **ហ៊ុន សែន**។ វិធានការរដ្ឋបាលសំខាន់ៗមួយចំនួនដែលបាន និងកំពុងបន្តអនុវត្តរួមមានដូចជា÷ (១) វិធានការពង្រឹងរដ្ឋបាលគយ និងរដ្ឋាករសម្រាប់រយៈពេល៦០ ថ្ងៃ (២)វិធានការបើកបៀវត្សក្នុងសប្តាហ៍ទី៤ នៃខែ (៣) វិធានការពង្រឹងការតាមដានវាយតម្លៃប្រតិបត្តិការការងារ តាមរយៈកិច្ចប្រជុំបូកសរុបការងារប្រចាំខែ (៤) វិធានការបិទតារាងបញ្ជីតម្លៃសេវា និងស្តង់ដារសាធារណៈ នៅតាមអង្គភាពផ្តល់សេវា (៥) វិធានការបិទស្លាកមិនតម្រូវឱ្យបង់ថ្លៃ សម្រាប់ការត្រួតពិនិត្យឯកសារនៅតាមការិយាល័យ (៦) វិធានការបង្កើតឱ្យមានបញ្ជរសេវាតែមួយ និងមិនអនុញ្ញាតឱ្យកាន់ឯកសារក្រៅពីមន្ត្រី (៧) កែលម្អគោលការណ៍ និងយន្តការផ្តល់ការលើកទឹកចិត្ត និង (៨) ការពង្រឹងយន្តការ និងកិច្ចប្រតិបត្តិការសវនកម្មផ្ទៃក្នុង។

លើសពីនេះ ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិសេស ដើម្បីជំរុញបញ្ចប់ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុនៃដំណាក់កាលទី២ នៅក្នុងឆ្នាំ២០១៥ នេះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានការទទួលខុសត្រូវក្នុងការដាក់ឱ្យអនុវត្តប្រព័ន្ធព័ត៌មានវិទ្យា ការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មី ប្លង់គណនីថ្មី និងការដាក់ឱ្យអនុវត្តសាកល្បងអង្គភាពថវិកា និងថវិកាកម្មវិធីពេញលេញនៅក្រសួងចំនួន១០។ ការងារទាំងនេះសុទ្ធសឹងតែជាការងារថ្មី និងស្មុគស្មាញ ដែលទាមទារឱ្យមានការផ្លាស់ប្តូរក្នុងការដឹកនាំ ការគ្រប់គ្រង ព្រមទាំងការពង្រឹងសមត្ថភាពជំនាញដល់មន្ត្រីរាជការនៅគ្រប់ក្រសួងស្ថាប័នទាំងអស់។ ទន្ទឹមនឹងផ្ទៃករឹង ដែលជាសមាសធាតុសម្រាប់បង្កើតប្រព័ន្ធផ្ទៃកទន់នៃ ការកែទម្រង់គឺជាកត្តាចាំបាច់មិនអាចខ្វះបានក្នុងការកំណត់ជោគជ័យ និងធានានិរន្តរភាពនៃការអនុត្តប្រព័ន្ធនោះ គឺការប្តេជ្ញាចិត្ត ឆន្ទៈកែទម្រង់ ភាពជាអ្នកដឹកនាំ ភាពជាម្ចាស់ និងការទទួលខុសត្រូវពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ ដែលមិនមែនគ្រាន់តែជាការងារថ្មីប៉ុណ្ណោះទេ តែជាការងារលំបាក ស្មុគស្មាញនិងត្រូវប្រឈមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាំងមូល ពិសេស គឺសម្រាប់ថ្នាក់ដឹកនាំទាំងអស់របស់ក្រសួង។

ពិតណាស់ថា ស្ថានភាពនយោបាយ សេដ្ឋកិច្ចសង្គម និងពិសេស យុទ្ធសាស្ត្រការទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល តម្រូវឱ្យគ្រប់ក្រសួង ស្ថាប័នបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន ប៉ុន្តែយើងសង្កេតឃើញថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិតជាមានចក្ខុវិស័យ និងសុឆន្ទៈយ៉ាងពិតប្រាកដក្នុងការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ពិសេសការអនុវត្តអភិក្រម **ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល និងព្យាបាល** ព្រមទាំងការបំពាក់ស្មារតីការងារ៤ យ៉ាងនៅក្នុងចំណោមមន្ត្រីនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺ **(១) ត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ, (២) ត្រូវប្រកាន់យកស្មារតីស្ថាប័ន (ធ្វើការជាក្រុម), (៣) មិនមើលរំលងកំហុសរបស់ខ្លួន និង (៤) ប្រកាន់អភិក្រមបុរេសកម្មក្នុងការបំពេញការងារ៕**


អង្គការលេខរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
រដ្ឋមន្ត្រី
រដ្ឋលេខាធិការ
អនុរដ្ឋលេខាធិការ
ខុទ្ទកាល័យ
ទីប្រឹក្សា
អគ្គលេខាធិការដ្ឋាន
នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
នាយកដ្ឋានបុគ្គលិក
នាយកដ្ឋាននីតិកម្ម
នាយកដ្ឋានព័ត៌មានវិទ្យា
នាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍
វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
នាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងសារពើពន្ធ
នាយកដ្ឋានស្ថិតិ
នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ចនិងអាស៊ាន
អគ្គនាយកដ្ឋានថវិកា
នាយកដ្ឋានកិច្ចការទូទៅ
នាយកដ្ឋានថវិកានីយកម្ម
នាយកដ្ឋានហិរញ្ញកិច្ច
នាយកដ្ឋានវិនិយោគ
នាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុល
អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
នាយកដ្ឋានគ្រប់គ្រងរដ្ឋបាលនិងបច្ចេកទេស
នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលរាជធានី ខេត្ត
នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលក្រុងស្រុក
នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
នាយកដ្ឋានរដ្ឋបាលបុគ្គលិកនិងផែនការ
នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មទំនិញ
នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មសំណង់និងសេវា
នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ
នាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ
អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
នាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រង
នាយកដ្ឋានផែនការ បច្ចេកទេសនិងកិច្ចការអន្តរជាតិ
នាយកដ្ឋានកិច្ចការច្បាប់ សវនកម្មនិងទំនាក់ទំនងសាធារណៈ
នាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើស
នាយកដ្ឋានរដ្ឋាករ
នាយកដ្ឋានរបបគយ
នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ
លេខាធិការដ្ឋាន
ថ្នាក់មូលដ្ឋាន
អគ្គនាយកដ្ឋានពន្ធដារ
នាយកដ្ឋានបុគ្គលិកនិងរដ្ឋបាលហិរញ្ញវត្ថុ
នាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ
នាយកដ្ឋានសេវាកម្មជាប់ពន្ធនិងចំណូលពន្ធ
នាយកដ្ឋានត្រួតពិនិត្យ
នាយកដ្ឋានព័ត៌មានវិទ្យា
នាយកដ្ឋានរបបគយគ្រប់គ្រងអ្នកជាប់ពន្ធធំ
នាយកដ្ឋានសវនកម្មសហគ្រាស
ថ្នាក់មូលដ្ឋាន
អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ
នាយកដ្ឋានសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ
នាយកដ្ឋានចំណូលពីទ្រព្យសម្បត្តិរដ្ឋ
នាយកដ្ឋានចំណូលសាធារណៈ
នាយកដ្ឋានសហគ្រាសសាធារណៈ
អគ្គនាយកដ្ឋានរតនាគារជាតិ
នាយកដ្ឋានរដ្ឋបាលនិងបុគ្គលិក
នាយកដ្ឋានចំណូលនិងចំណាយថវិកា
នាយកដ្ឋានគណនេយ្យ
នាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាននិងសរុបស្ថិតិ
នាយកដ្ឋានព័ត៌មានវិទ្យា
អធិការកិច្ចរតនាគារ
នាយកដ្ឋានគ្រប់គ្រងសាច់ប្រាក់និងវិភាគការអនុវត្តថវិកា
ថ្នាក់មូលដ្ឋាន
អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
នាយកដ្ឋានធានារ៉ាប់រងនិងសោធន
នាយកដ្ឋានទីផ្សារនិងស្ថាប័នហិរញ្ញវត្ថុ
នាយកដ្ឋានគ្រប់គ្រងអាជីវកម្មភ្នាល់និងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុបញ្ចាំនិងអនុប្បទាន
អគ្គាធិការដ្ឋាន
នាយកដ្ឋានរដ្ឋបាលផែនការនិងសិក្សាស្រាវជ្រាវបណ្តឹង
នាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ជាតិ
នាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង
នាយកដ្ឋានសវនកម្មផ្ទៃក្នុងថ្នាក់កណ្តាល
នាយកដ្ឋានសវនកម្មផ្ទៃក្នុងថ្នាក់មូលដ្ឋាន

## វិធានការ៦០ ថ្ងៃ ដើម្បីបង្កើនស័ក្តិសិទ្ធភាព និង ប្រសិទ្ធភាពនៃការប្រមូលចំណូលគយ

ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដើម្បីឆ្ពោះទៅដំណាក់កាលទី៣ នោះការធានាភាពជឿទុកចិត្តបាននៃថវិកា ប្រកបដោយស្ថិរភាព ជាពិសេស ការអនុវត្តថវិកាក្នុងឆ្នាំ ផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី គឺជាលក្ខខ័ណ្ឌចាំបាច់មិនអាចអត់បាន។ នោះមានន័យថា ការអនុវត្តចំណូលនិងចំណាយក្នុងឆ្នាំត្រូវមានគម្លាតកាន់តែតូចទៅ ធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត ហើយលំហូរចំណូលនិងចំណាយក៏កាន់តែមានភាពរលូន និងតាមកាលកំណត់។

ក្នុងន័យនេះ រាជរដ្ឋាភិបាលដាក់ចេញនូវយុទ្ធសាស្ត្រកៀរគរចំណូលដើម្បីធានា មិនត្រឹមតែស្ថិរភាពចំណូលក្នុងឆ្នាំប៉ុណ្ណោះទេ តែដើម្បីធានាស្ថិរភាពចំណូលរយៈពេលមធ្យម ដែលជាមូលដ្ឋានដ៏សំខាន់ និងចាំបាច់បំផុតក្នុងការឆ្ពោះទៅពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធីឱ្យកាន់តែមានប្រសិទ្ធភាព និងស័ក្តិភាពក្នុងគោលដៅឆ្ពោះទៅរកប្រព័ន្ធថវិកាមួយដែលអាចធានាបម្រើប្រកបដោយប្រសិទ្ធភាព និងស័ក្តិភាពដល់ការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ការកៀរគរចំណូលឱ្យអស់សក្តានុពល គឺជាលក្ខខ័ណ្ឌចាំបាច់មិនអាចខ្វះបាន សម្រាប់ការពង្រឹងភាពជាម្ចាស់លើការអភិវឌ្ឍប្រទេស និងបំពេញឱ្យបានគ្រប់គ្រាន់ទៅនឹងតម្រូវការនៃការចំណាយសាធារណៈ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច ការផ្តល់ការងារជូនប្រជាពលរដ្ឋ តាមរយៈការបែងចែកឡើងវិញនូវផលទុនជាតិក្នុងក្របខ័ណ្ឌប្រព័ន្ធថវិកាជាតិដ៏សមស្របមួយ ដែលជាការចូលរួមវិភាគទានដល់ការសម្រេចបាននូវគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ហេតុនេះ ការពង្រឹងរដ្ឋបាលចំណូលមានវិសាលភាពគ្របដណ្តប់ទៅលើផ្នែកពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាល។

ដើម្បីសម្រេចបានតាមគោលដៅនៃក្របខ័ណ្ឌកម្មវិធីកែទម្រង់ឱ្យបានជាក់លាក់ និងមុតស្រួច រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវវិធានការ៦០ ថ្ងៃ ដើម្បីកាត់បន្ថយភាពអសកម្ម និងការលំបាកស្មុគស្មាញមួយចំនួនក្នុងការអនុវត្តនីតិវិធីគយ និងការទប់ស្កាត់និងបង្ក្រាបអំពើរត់គេចពន្ធតាមរូបភាពផ្សេងៗ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាតាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ជាពិសេសគឺការលើកកម្ពស់វប្បធម៌បង់ពន្ធ ការបង្ក្រាបអំពើរត់ពន្ធនិងការគេចពន្ធគ្រប់រូបភាពឱ្យដល់ឬសគល់ជាមួយគ្នានឹងការកែលម្អអភិបាលកិច្ចនៅក្នុងរដ្ឋបាលគយ។

អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានកសាងផែនការសកម្មភាពសម្រាប់រយៈពេល៦០ ថ្ងៃ គិតចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ដោយបានដាក់ចេញនូវវិធានការ ដែលត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់និងម៉ត់ចត់ជាទីបំផុតមួយចំនួនរួមមាន (១) ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តនីតិវិធីគយ (២) ពង្រឹងការគ្រប់គ្រងមន្ត្រី (៣) ការចេញបទប្បញ្ញត្តិបន្ថែម (៤) ការពង្រឹងការទទួលខុសត្រូវការលើកទឹកចិត្ត និងការ

ដាក់ទណ្ឌកម្មមន្ត្រីគយនិងរដ្ឋាករ (៥) ការកំណត់មាត់ច្រកសមស្របសម្រាប់ទំនិញប្រទេសទីៗ (៦)ការកំណត់មុខសញ្ញាពាក់ព័ន្ធដែលមានហានិភ័យ (៧) ការពង្រឹងកិច្ចសហការគយជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ (៨) កិច្ចសហការជាមួយសមភាគីប្រទេសជាមិត្ត (៩) ការចុះត្រួតពិនិត្យការងាររបស់ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់តាមការិយាល័យ និងមាត់ច្រកនៃរាជធានី ខេត្ត និង (១០) ការជំរុញការចូលរួមរបស់វិស័យឯកជនក្នុងការទប់ស្កាត់និងបង្ក្រាបអំពើរត់គេចពន្ធ។

ជាលទ្ធផលរដ្ឋបាលគយបានទទួលលទ្ធផលវិជ្ជមានផង និងអវិជ្ជមានផង។ លទ្ធផលវិជ្ជមាន គឺចំណូលពន្ធ និងអាករគយបានកើនឡើង អភិបាលកិច្ចក្នុងអង្គភាពគយនិងរដ្ឋាករត្រូវបានកែលម្អ អំពើរត់គេចពន្ធជាពិសេស តាមមាត់ច្រកស្របច្បាប់ត្រូវបានកាត់បន្ថយស្ទើរតែទាំងស្រុង។ សហគមន៍អ្នកដឹកជញ្ជូនក៏ដូចជាជើងសាគយបានកែលម្អរបៀបរបបនៃការធ្វើអាជីវកម្មរបស់ខ្លួនពីរបបម៉ៅការមករបបពិតដោយចែកដាច់រវាងកាតព្វកិច្ចពន្ធ និងថ្លៃសេវាកម្ម និងបរិយាកាសធុរកិច្ចសមធម៌ត្រូវបានកែលម្អតាមរយៈការលើកតម្កើងអនុលោមភាពច្បាប់ភាព មិនរើសអើង និងអព្យាក្រឹត្យភាពរបស់រដ្ឋបាលគយ។ ផ្ទុយមកវិញ លទ្ធផលអវិជ្ជមានមួយចំនួនក៏បានកើតមានឡើងដែរ ដូចជាជនឱកាសនិយមមួយចំនួនបានឆ្លៀតឱកាសកេងប្រវ័ញ្ចដំឡើងថ្លៃទំនិញដោយគ្មានហេតុផលសមស្រប ក្នុងស្ថានភាពខ្វះខាតនូវយន្តការការពារអ្នកប្រើប្រាស់ (Consumer Protection Mechanism) ដ៏មានប្រសិទ្ធភាពមួយដូចប្រទេសក្នុងតំបន់។ បន្ថែមលើនេះទៀត មានការកកស្ទះទំនិញជាច្រើននៅតាមមាត់ច្រកព្រំដែន ដែលមានលក្ខណៈបណ្តោះអាសន្នរយៈពេលប្រមាណមួយសប្តាហ៍ដំបូងនៃការអនុវត្តផែនការសកម្មភាពនេះ ដែលធ្វើឱ្យខ្សែសង្វាក់ផ្គត់ផ្គង់ទំនិញមានភាពមិនច្បាស់លាស់ ច្របូកច្របល់រយៈពេលខ្លីបណ្តាលមកពីការផ្លាស់ប្តូររបៀបរបបរកស៊ីបែបម៉ៅការមកបែបរបបពិតទាំងលើប្រាក់ពន្ធ និងលើបន្ទុកចំណាយសេវាកម្មផ្សេងៗ ដែលតម្រូវឱ្យមានពេលវេលាតថ្លៃគ្នាឡើងវិញរវាងម្ចាស់ទំនិញ និងជើងសាគយ។ ពិនិត្យជារួម ការអនុវត្តផែនការសកម្មភាព៦០ ថ្ងៃ កន្លងមកនេះឃើញថា ទោះបីជាវិធានការមួយចំនួនពុំទាន់អនុវត្តបានពេញលេញនៅឡើយក្តីក៏ប្រសិទ្ធភាពនៃការងារគៀរគរចំណូលគយនិងរដ្ឋាករ ការបង្ក្រាបអំពើរត់ពន្ធនិងការពង្រឹងអភិបាលកិច្ចអង្គភាពគយនិងរដ្ឋាករ ត្រូវបានកែលម្អនិងលើកកម្ពស់គួរឱ្យកត់សម្គាល់។ ចំណូលគយនិងរដ្ឋាករ ដែលប្រមូលបានក្នុងអំឡុងវិធានការ ៦០ ថ្ងៃបានកើនឡើងកម្រិតខ្ពស់ប្រមាណជាង២៥% ធៀបទៅនឹងរយៈពេលដូចគ្នាឆ្នាំ២០១២។

ដោយមើលឃើញពីប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃវិធានការ៦០ ថ្ងៃ ដែលបានដាក់ចេញមកនោះរដ្ឋបាលគយនៅតែអនុវត្តលើវិធានការនេះបន្តទៀតដើម្បីរក្សាកំណើននៃការប្រមូលចំណូលគយ៕

## វិធានការ១ ខែ មាន២៨ ថ្ងៃ នៃការបើកបៀវត្ស

ការសម្រេចបានជាសារវន្តនូវភាពជឿទុកចិត្តបាន នៃថវិកា គឺជាជោគជ័យដ៏ធំធេងនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី១ ដែលបានផ្តល់លទ្ធភាពឱ្យរាជរដ្ឋាភិបាលកម្ពុជាអាចដោះស្រាយបាននូវបញ្ហាធំៗមួយចំនួនដូចជា (១) លុបបំបាត់បានទាំងស្រុងនូវបំណុលសាច់ប្រាក់ភ្ញុំរ៉ៃ (២)ទប់-ទល់បាននូវឥទ្ធិពលវិបត្តិសេដ្ឋកិច្ចពិភពលោក (៣) ដោះស្រាយបាននូវវិបត្តិព្រំដែនកម្ពុជា-ថៃ (៤) ដោះ-ស្រាយគ្រោះទឹកជំនន់ (៥) បង្កើនប្រាក់បៀវត្ស និងបើកបៀវត្សបានទាន់ពេលវេលា។

ទោះជាកម្រិតបៀវត្សរបស់មន្ត្រីរាជការបច្ចុប្បន្ននៅមិនទាន់ឆ្លើយតបទៅនឹងតម្រូវការនៅឡើយ ប៉ុន្តែរាជ-រដ្ឋាភិបាលបានខំប្រឹងប្រែងរៀបចំគោលនយោបាយបៀវត្ស ដើម្បីធានាដល់ការចំណាយឱ្យបានទាន់ពេលវេលា ដែលក្នុងនោះ ការចំណាយលើប្រាក់បៀវត្សជាអាទិភាពមួយរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់ស្មារតីការងារ និងស្មារតីសតិអារម្មណ៍របស់មន្ត្រីរាជការ។ កន្លងមកយើងសង្កេតឃើញថា មន្ត្រីរាជការបានរង់ចាំការបើកប្រាក់បៀវត្សរបស់ខ្លួនរហូតដល់៦០ ទៅ៩០ ថ្ងៃទើបអាចបើកប្រាក់បាន។ ប៉ុន្តែមកដល់ពេលនេះ ការបើកប្រាក់បៀវត្សមន្ត្រីរាជការលែងចោទជាបញ្ហាទៀតហើយ។ ផ្អែកតាមលទ្ធផលជាផ្លែផ្កានៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងស្ថិរភាពសាច់ប្រាក់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានដាក់វិធានការដល់ក្រសួងពាក់ព័ន្ធសំខាន់ៗមានដូចជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ ឱ្យកំណត់បើកបៀវត្សមិនឱ្យលើសពីសប្តាហ៍ទី៤ នៃខែនីមួយៗ តាមរយៈយន្តការ (១) ក្រសួងមុខងារសាធារណៈចេញតារាងបៀវត្សប្រចាំខែ និងតារាងកាត់ពន្ធលើបៀវត្សប្រចាំខែរបស់មន្ត្រីរាជការស៊ីវិលទៅឱ្យក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពចំណុះ យ៉ាងយូរត្រឹមដំណាច់សប្តាហ៍ទី២ នៃខែនីមួយៗ ដើម្បីក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពចំណុះ អាចបោះផ្សាយអាណត្តិបើកប្រាក់បៀវត្សប្រចាំខែ រួចបញ្ជូនមកអគ្គនាយកដ្ឋានថវិកា និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់ថ្នាក់កណ្តាល និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងរតនាគាររាជធានី ខេត្ត សម្រាប់ថ្នាក់រាជធានី ខេត្ត (២) មន្ត្រីរាជការភាគ-ច្រើនបានបើកប្រាក់បៀវត្សដល់ដៃ និងទាន់ពេលវេលា ដោយមិនឱ្យឆ្លងខែនីមួយៗឡើយ ដោយសារក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានកំណត់ការបើកបៀវត្សតាមប្រព័ន្ធធនាគារ និងតាមតារាងពេលវេលាតាមលំដាប់ថ្ងៃគឺយ៉ាងយូរត្រឹមថ្ងៃទី៥ នៃសប្តាហ៍ទី៤ សម្រាប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ទីរ និងអង្គភាពចំណុះ។ ការបើកផ្តល់បៀវត្សនេះត្រូវបានអនុវត្តតាមរយៈអនុស្សារណៈយោគយល់គ្នា (MoU) ជាមួយធនាគារកាណាឌីយ៉ា ក.អ ធនាគារអេស៊ីលីដាភីអិលស៊ី និងក្រុមហ៊ុនវីងខេមបូឌាលីមីធីត។

គួរកត់សម្គាល់ថា ការបើកបៀវត្សបានទាន់ពេលវេលា និងតាមប្រព័ន្ធធនាគារមិនអាចប្រព្រឹត្តទៅបានឡើយ ប្រសិនបើពុំមានជោគជ័យក្នុងដំណាក់កាលទី១

នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺភាពជឿទុកចិត្តបាននៃថវិកា ដែលបានប្រែក្លាយស្ថានភាពបំណុលសាច់ប្រាក់កកស្ទះដ៏រ៉ាំរ៉ៃទៅជាស្ថានភាពអតិរេកសាច់ប្រាក់។

លើសពីនេះទៅទៀត ដើម្បីកាត់បន្ថយនីតិវិធីវែងឆ្ងាយ និងស្មុគស្មាញ និងចំណាយខ្ជះខ្ជាយនោះ រាជរដ្ឋាភិបាលបានចាត់វិធានការដូចខាងក្រោម (១) សម្រេចលុបចោលអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលដោយព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/៩៥៦ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៣ និងសម្រេចដាក់ឱ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងមុខងារសាធារណៈដោយផ្ទេរ និងធ្វើសមាហរណកម្មអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ទៅក្នុងក្រសួងមុខងារសាធារណៈវិញ (២) បង្កើត**ក្រុមការងារកែទម្រង់ប្រព័ន្ធបៀវត្ស** ដែលមានសមាសភាពពីក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយបានចេញសារាចរស្តី**ពីការកំណត់នីតិវិធី សម្រាប់ការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិល**។ ទន្ទឹមនឹងនេះ ដើម្បីអនុវត្តសារាចររបស់រាជរដ្ឋាភិបាលខាងលើឱ្យមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ចេញនូវ *សារាចរណែនាំស្តីពីការអនុវត្តនីតិវិធី សម្រាប់ការបើកផ្តល់បៀវត្សប្រចាំខែជូនមន្ត្រីរាជការស៊ីវិល នគរបាលជាតិ យោធិន និងប្រាក់កម្រៃរបស់មន្ត្រីជាប់កិច្ចសន្យា ឬ បុគ្គលិកអណ្តែត ព្រមទាំងប្រាក់ឧបត្ថម្ភរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងបង្កើតគណៈកម្មការចម្រុះទទួលបន្ទុកគម្រោងការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារ*។

## ពីលេខាធិការដ្ឋានទៅអគ្គលេខាធិការដ្ឋានៈ តើមានអ្វីថ្មី ?

លេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានរៀបចំតម្លើងទៅជាអគ្គលេខាធិការដ្ឋាននៅក្នុងអាណត្តិទី៥របស់រាជរដ្ឋាភិបាល។ ពិតជាមានការផ្លាស់ប្តូរជាគុណភាព គឺមិនមែនគ្រាន់តែជារូបភាពដែលឃើញថាពីប្រធានលេខាធិការដ្ឋានជាប្រធាននាយកដ្ឋានទៅជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ដែលជាអនុរដ្ឋលេខាធិការនោះទេ។ ជាក់ស្តែង ស្ទើរតែមុខងារ និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋានក៏ត្រូវបានកែលម្អ និងបន្ថែមឱ្យកាន់តែច្បាស់ ស្រួច និងមានវិសាលភាពទូលាយជាងមុន ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៃដំណាក់ការថ្មីនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាដំណាក់កាលថ្មីនៃការកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលនៅក្នុងបរិការណ៍ថ្មីនៃស្ថានភាពនយោបាយសេដ្ឋកិច្ច និងសង្គមក្នុងអាណត្តិទី៥ នេះដែរ។ ទន្ទឹមនឹងការដើរតួនាទីជាអង្គភាពគ្រប់គ្រងគម្រោង និងការងារសម្របសម្រួលក្នុងការងាររៀបចំ និងតាមដានការអនុវត្តគម្រោង គឺអគ្គលេខាធិការដ្ឋានត្រូវបានបន្ថែមមុខងារជាអ្នកជំនាញ ទីប្រឹក្សា ជាអ្នកផ្សព្វផ្សាយ ជាអ្នកផ្តល់ចំណេះដឹង និងជាអ្នកផ្តួចផ្តើមគំនិតថ្មីសម្រាប់ការផ្លាស់ប្តូរ ក៏ដូចជាការដោះស្រាយបញ្ហាប្រឈមនានា ឆ្ពោះទៅរកស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព។

ដើម្បីបំពេញមុខងារនិងភារកិច្ចថ្មីនេះ អគ្គលេខាធិការដ្ឋានបានកំណត់នូវចក្ខុវិស័យរបស់ខ្លួន គឺប្តេជ្ញាប្រែក្លាយខ្លួនឱ្យទៅជាមជ្ឈមណ្ឌលដ៏ឧត្តម ដែលប្រមូលផ្តុំទៅដោយសមត្ថភាពជំនាញចំណាន មានវិជ្ជាជីវៈខ្ពស់ មានគុណធម៌ មានសីលធម៌ វិន័យ និងសេចក្តីថ្លៃថ្នូរ ក្នុងបុព្វហេតុចូលរួមបម្រើឧត្តមប្រយោជន៍សង្គមជាតិ។ គោលដៅឆ្ពោះទៅរកចក្ខុវិស័យនេះ គោលបំណងដ៏ចម្បង និងជាបឋមរបស់អគ្គលេខាធិការដ្ឋាន គឺការបំពេញមុខងារជាសេនាធិការរបស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយគុណភាព ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពក្នុងការកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅកាន់ស្តង់ដារអន្តរជាតិប្រកបដោយជោគជ័យ។ ក្នុងគោលដៅនេះអគ្គលេខាធិការដ្ឋានបានរៀបចំជាឯកសារចក្ខុវិស័យ និងយុទ្ធសាស្ត្រ ដើម្បីជាប្រទីបគោចរក្នុងការអនុវត្តការងាររបស់ខ្លួន ដែលរួមមានចក្ខុវិស័យ គោលបំណង លទ្ធផលចុងក្រោយ ផែនការសកម្មភាព និងថវិកា ការត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្ម បទបញ្ជាផ្ទៃក្នុង និងវិន័យការងារ ព្រមទាំងរចនាសម្ព័ន្ធ និងកិច្ចដំណើរការការងាររបស់អគ្គលេខាធិការដ្ឋាន។ ឯកសារនេះត្រូវបានរៀបចំ និងពិនិត្យពិភាក្សាអនុម័តដោយអគ្គលេខាធិការដ្ឋានតាមរយៈការធ្វើវិបស្សនា ហើយដែលនឹងត្រូវយកមកពិនិត្យវាយតម្លៃ និងកែលម្អប្រចាំឆ្នាំ តាមរយៈការធ្វើវិបស្សនាមុននឹងដាក់សុំការសម្រេចឯកភាពដាក់ឱ្យអនុវត្តដោយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ៕

## ការកែទម្រង់ប្រព័ន្ធថវិកា គឺជាស្នូលនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ថវិកា គឺជាឧបករណ៍នៃគោលនយោបាយ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែងរដ្ឋាភិបាលនៃប្រទេសភាគច្រើននៅតែមានការលំបាកក្នុងការធានា និងធ្វើឱ្យសាធារណជនមានជំនឿថា ថវិការបស់រដ្ឋាភិបាល គឺពិតជាឧបករណ៍របស់គោលនយោបាយ ហើយការអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាល គឺពិតជាដើម្បីបម្រើឱ្យប្រជាពលរដ្ឋប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពប្រាកដមែន។ ម៉្យាងទៀត សូម្បីតែការគោរពគោលការណ៍ថវិកាដ៏សំខាន់៣ គឺវិន័យថវិកា (រក្សាតុល្យភាព និងចីរភាព) ប្រសិទ្ធភាពវិភាជន៍ថវិកា (ធានាការវិភាជចំគោលដៅអាទិភាព) និងប្រសិទ្ធភាពបច្ចេកទេសនៃការប្រើប្រាស់ថវិកា (ធានាការប្រើប្រាស់ថវិកាប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព) ក៏រដ្ឋាភិបាលនៃបណ្តាប្រទេសមួយចំនួននៅតែពុំទាន់អាចគោរពបានពេញលេញនៅឡើយ។ ជាក់ស្តែង ប្រទេសភាគច្រើនមកដល់ពេលនេះនៅតែប្រឈមនឹងការធានាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ឬ/និង ទៅនឹងសកម្មភាព ឬ/និង សមិទ្ធកម្ម ទោះជាប្រទេសអភិវឌ្ឍន៍ដែលមានប្រព័ន្ធគ្រប់គ្រងថវិកាប្រកបដោយកម្រិតស្តង់ដារអន្តរជាតិ មានបច្ចេកវិទ្យាទាន់សម័យ និងមានសមត្ថភាពស្ថាប័ន និងធនធានមនុស្សកម្រិតខ្ពស់ក៏ដោយ។ តួយ៉ាងដូចជាបញ្ហាវិបត្តិបំណុលសាធារណៈ និងឱនភាពថវិកាខ្ពស់ហួសហេតុ

នៃបណ្តាប្រទេសមួយចំនួន ព្រមទាំងការចំណាយខ្ពស់ហួសព្រំដែនលើវិស័យមួយចំនួនដូចជា វិស័យយោធា និងប្រព័ន្ធសុវត្ថិភាពសង្គម ដែលបានធ្វើឱ្យប្រទេសទាំងនោះធ្លាក់ទៅក្នុងវិបត្តិហិរញ្ញវត្ថុសាធារណៈធ្ងន់ធ្ងរដោយ-សារតែការធ្វេសប្រហែសក្នុងការគោរពគោលការណ៍ថវិកាដ៏សំខាន់ទាំង៣ ដូចបានគូសបញ្ជាក់ខាងលើ។

ទោះជាយ៉ាងណា បច្ចុប្បន្នប្រព័ន្ធគ្រប់គ្រងហិរញ្ញ-វត្ថុសាធារណៈ ឬ ប្រព័ន្ធគ្រប់គ្រងថវិកាដែលកំពុងពេញនិយម ហើយដែលប្រទេសភាគច្រើនបាននិងកំពុងប្រឹងប្រែងកសាងឆ្ពោះទៅរក ឬ បាននិងកំពុងបន្តកែលម្អឱ្យកាន់តែប្រសើរឡើងតាមរយៈកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនោះ គឺប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬ ប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល ឬ សមិទ្ធកម្ម (Result or Performance Based Public Finance Management or Budgeting System)។ ប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល ឬ សមិទ្ធកម្មនេះ គឺជាប្រព័ន្ធដែលផ្សារភ្ជាប់ការវិភាជថវិកាទៅនឹងសកម្មភាពជាក់ស្តែង និងកម្មវិធីច្បាស់លាស់ទៅនឹងគោលបំណងគោលនយោបាយអាទិ-ភាពរបស់ក្រសួង ស្ថាប័ន និងជាពិសេស ទៅនឹងគោល-បំណងគោលនយោបាយតាមវិស័យ និងរបៀបវារៈគោលនយោបាយថ្នាក់ជាតិរបស់រដ្ឋាភិបាល ដើម្បីធានាថា **ថវិកាជាតិពិតជាដើរតួនាទីជាឧបករណ៍នៃគោលនយោបាយរបស់រដ្ឋាភិបាលប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពប្រាកដមែន។**

ស្របតាមនិន្នាការជាសកលនេះ រាជរដ្ឋាភិបាលបានប្តេជ្ញាធ្វើការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារ-ណៈរបស់ខ្លួនឆ្ពោះទៅរកស្តង់ដារអន្តរជាតិ **ពោលគឺការផ្លាស់ប្តូរជាបណ្តើរៗពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬ ប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើធាតុចូលនិងមជ្ឈការ ឆ្ពោះទៅប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬ ប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល ឬ សមិទ្ធកម្មនិងវិមជ្ឈការ** តាមរយៈកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធាណៈដែលជាកម្មវិធីរយៈពេលវែង មានលក្ខណៈគ្រប់ជ្រុងជ្រោយ និងអនុវត្តតាមយុទ្ធសាស្ត្រ៤ ជំហាន ឬ/និង៤ ដំណាក់កាលគឺ ***(១) ការបង្កើនភាពជឿទុកចិត្តលើថវិកា (២) ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ (៣) ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និង (៤) ការបង្កើនគណនេយ្យភាពសមិទ្ធកម្ម***។ ដំណាក់កាលទី១ ត្រូវបានចាប់ផ្តើមដាក់ឱ្យអនុវត្តនៅចុងឆ្នាំ២០០៤ និងត្រូវបានអនុវត្តពេញលេញនៅឆ្នាំ២០០៥ ហើយត្រូវបានបញ្ចប់ដោយជោគជ័យជាមួយនឹងការប្រកាសដាក់ឱ្យអនុវត្តដំណាក់កាលទី២ នៅចុងឆ្នាំ២០០៨ ហើយដែលគ្រោងនឹងបញ្ចប់នៅចុងឆ្នាំ២០១៥ បន្ទាប់ពីការដាក់ឱ្យអនុវត្តជំហានទី១ នៃប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុបានចប់សព្វគ្រប់។ ដំណាក់កាលទី៣ នឹងត្រូវដាក់ឱ្យអនុវត្ត ព្រមជាមួយនឹងការបញ្ចប់ដំណាក់កាលទី២ នៅឆ្នាំ២០១៦ ជាមួយនឹងការចាប់ផ្តើមជំហានទី១នៃការកែទម្រង់ប្រព័ន្ធថវិកានៅដើមឆ្នាំ២០១៥ ដែលនឹងត្រូវដាក់ឱ្យអនុវត្តពេញលេញនៅឆ្នាំ២០២០ ហើយដែលការកែទម្រង់ប្រព័ន្ធថវិកានេះ នឹងក្លាយជាកម្លាំងចលករដ៏សំខាន់ សម្រាប់ដំណាក់កាលទី៣ ដែលគ្រោង

នឹងបញ្ចប់នៅចុងឆ្នាំ២០២០ ជាមួយនឹងការដាក់ឱ្យអនុវត្តដំណាក់កាលទី៤ ដែលសង្ឃឹមថា អាចនឹងបញ្ចប់ជាស្ថាពរនូវគោលដៅទាំងបួននៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូលនៅឆ្នាំ២០២៥។ ដើម្បីជាមូលដ្ឋាន និងជាប្រទីបគោចររាជរដ្ឋាភិបាលបានដាក់ចេញនូវឯកសារទស្សនាទានស្តីអំពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ២០១៣-២០២០ ដែលជាស្នូលនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិសេស សម្រាប់ដំណាក់កាលទី៣ និងទី៤ និងដែលត្រូវបន្តអនុវត្តជាជំហានៗ និងជាដំណាក់ៗ ដើម្បីធានាដល់**ការផ្លាស់ប្តូរជាបណ្តើរៗនូវប្រព័ន្ធគ្រប់គ្រងថវិកាកម្ពុជាពីការផ្តោតលើធាតុចូលនិងមជ្ឈការ ទៅជាការផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការឱ្យបានជោគជ័យតាមការគ្រោងទុកពីឆ្នាំ២០១៣ ដល់ឆ្នាំ២០២០** ពោលគឺការកែលម្អទៅលើដំណាក់កាលសំខាន់ទាំងបួននៃវដ្តថវិកា គឺការរៀបចំថវិកា ការអនុម័តថវិកា ការអនុវត្តថវិកា និងការត្រួតពិនិត្យ តាមដាន វាយតម្លៃលទ្ធផល។ ទន្ទឹមនឹងនេះ ប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល ឬ សមិទ្ធកម្មនេះអាចអនុវត្តទៅបានសម្រេចតាមគោលដៅ គឺទាមទារឱ្យមានសមត្ថភាពមន្ត្រី និងស្ថាប័នសមស្រប មានប្រព័ន្ធប្រតិបត្តិការការងារប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព និងជាពិសេសមានប្រព័ន្ធគ្រប់គ្រងត្រួតពិនិត្យ តាមដាន និងវាយតម្លៃលទ្ធផលប្រកបដោយតម្លាភាព គណនេយ្យភាព និងការទទួលខុសត្រូវច្បាស់លាស់ ស័ក្តិសិទ្ធ និងប្រសិទ្ធភាព៕



## ក្រមនីយកម្ម ក្នុងវិស័យពន្ធដារ

កិច្ចការពារនីត្យានុកូលភាព គឺជា “កាតព្វកិច្ចធម្មនុញ្ញ” របស់រាជរដ្ឋាភិបាល ដែលត្រូវបានកំណត់ដោយមាត្រា៥២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងន័យនេះ រដ្ឋធម្មនុញ្ញបានបញ្ញត្តិកាតព្វកិច្ចកំពូលដល់រាជរដ្ឋាភិបាលឱ្យការពារការគោរពច្បាប់ និងការប្រតិបត្តិច្បាប់នៅក្នុងក្របខ័ណ្ឌនៃកិច្ចដំណើរការនៃការស្ថាបនានិងការពារ“នីតិរដ្ឋ”នៅព្រះរាជាណាចក្រកម្ពុជា។នៅក្នុងបុព្វហេតុធម្មនុញ្ញនេះ រាជរដ្ឋាភិបាលបានផ្តល់អាទិភាពខ្ពស់ជាប់ជានិច្ចចំពោះ“អភិបាលកិច្ចល្អ” ដែលត្រូវបានចារឹកទុកជាស្នូលនៃ “យុទ្ធសាស្ត្រចតុកោណ” របស់រាជរដ្ឋាភិបាលនៅក្នុងទិសដៅយុទ្ធសាស្ត្រទាំងបួនយ៉ាង គឺកំណើនការងារ សមធម៌ និងប្រសិទ្ធភាព។

ក្នុងនាមសេនាធិការរបស់រាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចដឹកនាំការរក្សាវិន័យហិរញ្ញវត្ថុសាធារណៈ និងការគោរពច្បាប់ហិរញ្ញវត្ថុ ដើម្បីធានាឱ្យគោលការណ៍គ្រឹះនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួន និងប្រកបដោយអភិបាលកិច្ចល្អ ជាពិសេស គោលការណ៍បូរណភាព សង្គតិភាព គណនេយ្យភាព និងតម្លាភាព។

គោលការណ៍បូរណភាព សង្គតិភាព គណនេយ្យភាព និងតម្លាភាព គឺជាគោលការណ៍គ្រឹះ និងចាំបាច់សម្រាប់ធានាឱ្យប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឱ្យមានលក្ខណៈពេញលេញ គ្រប់ជ្រុងជ្រោយ ប្រទាក់ក្រឡា មានការទទួលខុសត្រូវចំពោះមុខងារនៃរដ្ឋបាលគ្រប់លំដាប់ថ្នាក់ និងមានការផ្សព្វផ្សាយទូលំទូលាយ ព្រមទាំងធានាបាននូវការរៀបចំ និងការអនុវត្តនូវក្របខ័ណ្ឌគតិយុត្តប្រកបដោយសង្គតិភាពទាំងក្នុងកម្រិតគោលនយោបាយ និងកិច្ចសម្របសម្រួលស្ថាប័ន។

ក្នុងគោលដៅធានាការអនុវត្តគោលការណ៍គ្រឹះនៃអភិបាលកិច្ចល្អខាងលើ និងរួមចំណែកទ្រទ្រង់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព លិខិតបទដ្ឋានគតិយុត្តត្រូវតាក់តែងឡើងឱ្យមាននីត្យានុកូលភាព សង្គតិភាព និងសុខដុមភាព។

ចំពោះវិស័យពន្ធដារ គោលការណ៍នីត្យានុកូលភាពនៃពន្ធដារ គឺជា “គោលការណ៍ធម្មនុញ្ញ” ដែលបានចែងថា “ការយកពន្ធដារនឹងអាចធ្វើទៅបាន លុះត្រាតែមានច្បាប់អនុញ្ញាត” រីឯការបង្កើត ការកែប្រែ និងការលុបចោលពន្ធដារ ក៏ត្រូវធ្វើឡើងដោយច្បាប់ផងដែរ។

ការគោរពគោលការណ៍ធម្មនុញ្ញខាងលើនេះ ទាមទារជាចាំបាច់នូវការប្រមូលផ្តុំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទាំងអស់ ដែលស្ថិតនៅជាធរមាន និងពេញលេញសម្រាប់ធ្វើជា “ឧបករណ៍ទ្រទ្រង់អភិបាលកិច្ច” ក្នុងវិស័យពន្ធដារ។ ជាការឆ្លើយតបចំពោះសេចក្តីត្រូវការចាំបាច់នេះ “កម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធវិស័យពន្ធដារ”ត្រូវបានបង្កើតឡើងដោយប្រមូលផ្តុំរាល់លិខិតបទដ្ឋានគតិយុត្តជាធរមានក្នុងវិស័យពន្ធដារ ដោយអនុវត្តតាមឧត្តមានុវត្តន៍នៃវិធីសាស្ត្រ “ក្រមនីយកម្ម”។

“វិធីសាស្ត្រក្រមនីយកម្ម” គឺជាសំណុំបច្ចេកទេសគតិយុត្ត សម្រាប់រៀបចំចំណាត់ថ្នាក់អត្ថបទនៃបទដ្ឋាន

គតិយុត្តប្រកបដោយរចនាសម្ព័ន្ធជាក់លាក់ តាមតក្កវិជ្ជាគតិយុត្ត ដើម្បីសម្រេចបានជាកម្រងឯកសារមួយ ដែលមានមាតិកានុក្រមរួមតែមួយហៅថា "ក្រម"។ វិធីសាស្ត្រនេះ អនុញ្ញាតឱ្យមានការកែប្រែរចនាសម្ព័ន្ធនៃអត្ថបទគតិយុត្តដើម និរាករអត្ថបទគតិយុត្ត ឬ រៀបចំតាក់តែងបទប្បញ្ញត្តិឡើងវិញ ដើម្បីធានាការគោរពគោលការណ៍ឋានានុក្រមនៃបទដ្ឋានគតិយុត្ត បញ្ជាក់ឱ្យច្បាស់នូវបទប្បញ្ញត្តិស្រពេចស្រពិល និងបំពេញសុខដុមនីយកម្មនៃបទដ្ឋានគតិយុត្ត ដែលកំពុងស្ថិតនៅជាធរមាន។

ដោយឡែក វិធីសាស្ត្រខាងលើ មិនត្រូវបានយកមកអនុវត្តទាំងស្រុងឡើយសម្រាប់រៀបចំចងក្រងកម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធវិស័យពន្ធដារ" នេះ ដោយហេតុថា កម្រងនេះត្រូវបានរៀបចំឡើង ដោយគោរពយ៉ាងខ្ជាប់ខ្ជួននូវអត្ថបទដើមទាំងស្រុង និងប្រមូលផ្តុំអត្ថបទគតិយុត្តជាធរមានទៅតាមចំណាត់ថ្នាក់គតិយុត្តប្រកបដោយតក្កវិជ្ជាគតិយុត្ត។

ដោយអនុវត្តតាមវិធីសាស្ត្រខាងលើ កម្រងសម្រង់ត្រូវបានចែកចេញជា១៧ គន្ថី ដែលប្រមូលផ្តុំបទដ្ឋានគតិយុត្តទៅតាមជំពូកគតិយុត្តដូចតទៅ គឺ÷ បទប្បញ្ញត្តិមូលដ្ឋាន វិធាននិងនីតិវិធីសារពើពន្ធ ពន្ធលើប្រាក់ចំណេញ ពន្ធលើប្រាក់បៀវត្ស ពន្ធប៉ាតង់ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ពន្ធប្រថាប់ត្រា ពន្ធលើអចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ពន្ធលើឈ្នួលផ្ទះនិងដី ពន្ធសត្តឃាតអាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញនិងសេវាមួយចំនួន អាករលើផលរបរ អាករលើការស្នាក់នៅ អាករបំភ្លឺសាធារណៈ និងតែមប្រើសារពើពន្ធ។

គន្ថីនីមួយៗត្រូវបានបែងចែកជាមាតិកា ដែលប្រមូលផ្តុំលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយរៀបចំជាលំដាប់លំដោយ ទៅតាមឋានានុក្រមគតិយុត្តពីខ្ពស់មកទាប ពោលគឺ ច្បាប់ អនុក្រឹត្យ សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ប្រកាស សេចក្តីសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសារាចរ។

មាតិកានីមួយៗ ប្រមូលផ្តុំអត្ថបទគតិយុត្តពាក់ព័ន្ធនឹងចំណាត់ថ្នាក់គតិយុត្ត នៃគន្ថីនីមួយៗ ទៅតាមលំដាប់កាលប្បវត្តិ ឬ តាមកម្មវត្ថុគតិយុត្ត។ ចំពោះច្បាប់ និងអនុក្រឹត្យ មានតែបទប្បញ្ញត្តិពាក់ព័ន្ធនឹងប្រភេទគតិយុត្តនៃគន្ថីនីមួយៗប៉ុណ្ណោះ ដែលត្រូវបានបញ្ចូលដោយក្នុងនោះរួមមានមូលបទ បទប្បញ្ញត្តិទូទៅ មាត្រាពាក់ព័ន្ធអន្តរប្បញ្ញត្តិនិងអវសានប្បញ្ញត្តិ។

នៅដើមគន្ថី និងមាតិកានីមួយៗ មានអត្ថបទជាសេចក្តីផ្តើម ដែលរៀបរាប់អំពីអត្ថបទគតិយុត្តពាក់ព័ន្ធដែលស្ថិតនៅជាធរមាន ត្រូវបានធ្វើវិសោធនកម្ម ឬ ត្រូវបាននិរាករ ដែលអាចជានិរាករណ៍ដោយជាក់លាក់ ឬ និរាករណ៍ដោយតុណ្ហីភាព។

ទន្ទឹមនឹងការចម្លងតាមច្បាប់ដើមទាំងស្រុង កម្រងនេះក៏ត្រូវបានផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធ ដោយអនុលោមតាមវចនានុក្រមខ្មែរ និងវាក្យសព្ទថ្មីៗ ដែលត្រូវបាននិងកំពុងប្រើប្រាស់នាពេលបច្ចុប្បន្នផងដែរ។ ក្នុងករណីមានភាពខុសគ្នារវាងអត្ថបទដើមដែលមានបោះត្រា និងអត្ថបទដែលចុះផ្សាយក្នុងរាជកិច្ច អត្ថបទដើមមានបោះត្រាត្រូវបានយកមកធ្វើជាមូលដ្ឋានសម្រាប់ការចម្លងតាមនេះ។

# ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

"កម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធវិស័យពន្ធដារ" គឺជាការប្រមូលផ្តុំលិខិតបទដ្ឋានគតិយុត្តពាក់-ព័ន្ធនឹងសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ កម្រងនេះ ត្រូវបានរៀបចំឡើងទៅតាមដំណាក់កាលចំនួន៧ ជាបន្តបន្ទាប់ដូចខាងក្រោមគឺ÷

- ស្វែងរកឯកសារ
- កំណត់ធរមានប្បញ្ញត្តិ
- ចម្លងតាមអត្ថបទដើមទាំងស្រុង
- រៀបចំអត្ថបទ តាមចំណាត់ថ្នាក់ឬជំពូកគតិយុត្ត
- ពិនិត្យនិងកត់ត្រាអំពីស្ថានភាពធរមានប្បញ្ញត្តិនៃអត្ថបទគតិយុត្ត
- ពិនិត្យ ផ្ទៀងផ្ទាត់ និងកត់ត្រាកំហុសឆ្គង ឬកង្វះចន្លោះ ទៅក្នុង "សង្កេត"
- ពិនិត្យ និងផ្ទៀងផ្ទាត់បញ្ចប់លើគ្រប់ទិដ្ឋភាព (អក្ខរាវិរុទ្ធ ស្ថានភាពធរមានប្បញ្ញត្តិ ភាពត្រឹមត្រូវតាមអត្ថបទដើម សង្កេត ទម្រង់នៃអត្ថបទគតិយុត្ត សោភ័ណភាពទូទៅ និងការបញ្ចូលក្នុងកម្មវិធីសម្រាប់ការបោះពុម្ព)។

កម្រងសម្រង់នេះ ត្រូវបានសម្រេចឡើងតាម ៥ កម្រិតដូចតទៅ÷

- ការរៀបចំកម្រិតជំនាញធម្មតា
- ការពិនិត្យនិងផ្ទៀងផ្ទាត់តាមវិស័យ
- ការពិនិត្យនិងផ្ទៀងផ្ទាត់ជារួម
- ការពិនិត្យនិងផ្ទៀងផ្ទាត់បញ្ចប់
- ការពិនិត្យនិងអនុម័ត។

"កម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធវិស័យពន្ធដារ" ត្រូវបានបង្ហាញឡើងតាមលំដាប់លំដោយដូចខាងក្រោម÷

- បុព្វកថា
- សេចក្តីផ្តើម
- មាតិកានុក្រម
- តួសេចក្តីនៃកម្រងសម្រង់
- គន្ថនិទ្ទេស ជាបញ្ជីអត្ថបទគតិយុត្តភ្ជាប់ជាមួយនឹងប្រភពនៃអត្ថបទនីមួយៗ
- កាលប្បវត្តិ ជាបញ្ជីអត្ថបទគតិយុត្តដែលត្រូវបានរៀបចំតាមលំដាប់នៃកាលបរិច្ឆេទនៃអត្ថ-បទនីមួយៗ។

កម្រងសម្រង់នេះអាចនឹងក្លាយជាឧបករណ៍គន្លឹះមួយរួមចំណែកទ្រទ្រង់អភិបាលកិច្ច ដែលអាចជួយសម្រួលដល់ការបំពេញមុខងារ និងភារកិច្ចរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាពិសេស អគ្គនាយកដ្ឋានពន្ធដារ ក៏ដូចជាក្រសួងស្ថាប័នផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជាផង និងរួមចំណែកពង្រឹង **"វប្បធម៌បង់ពន្ធ"** សម្រាប់ប្រជាពលរដ្ឋទូទៅ រួមទាំង អាជីវករ ពាណិជ្ជករ វិនិយោគិនធុរជននានាផង ព្រមទាំងជួយផ្តល់វិភាគទានខាងពុទ្ធិដល់ការយល់ដឹង ការរៀនសូត្រ និងសិក្សាស្រាវជ្រាវរបស់និស្សិត សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ បញ្ញវន្តនិងសាធារណជនជាទូទៅផងដែរ៕

## យុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈនៅកម្ពុជា

ក្នុងស្ថានភាពដែលសេដ្ឋកិច្ចកម្ពុជាបាន និងកំពុងត្រូវការការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលមានផលិតភាពខ្ពស់ និងធានាចីរភាពកំណើន រាជរដ្ឋាភិបាល មិនគ្រាន់តែមើលឃើញសក្តានុពលប្រភពហិរញ្ញប្បទានវិនិយោគសាធារណៈដោយវិស័យឯកជន និងការខ្ចីបុលប៉ុណ្ណោះទេ តែថែមទាំងបានយល់ច្បាស់អំពីសារៈសំខាន់នៃការធានាឱ្យការគ្រប់គ្រងបំណុលសាធារណៈប្រកបដោយចីរភាព តាមរយៈការដាក់ចេញនូវវិធានការចាំបាច់នានាជាបន្តបន្ទាប់ ហើយដើម្បីបន្តបង្កើនការតម្រង់ទិសនៃការខ្ចី និងការប្រើប្រាស់ឥណទានឱ្យចំទិសដៅអាទិភាពឱ្យកាន់តែមានប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលបានរៀបចំ និងដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈនៅកម្ពុជា ដែលជារួមបានចង្អុលទិសដោយផ្អែកលើគោលនយោបាយ និងគោលការណ៍គន្លឹះសំខាន់៤ គឺ (១) ត្រូវខ្ចីឥណទានក្នុងទំហំសមស្រប ដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន (២) ត្រូវខ្ចីតែឥណទាន ដែលមានកម្រិតសម្បទានខ្ពស់ (៣) ត្រូវខ្ចីសម្រាប់តែវិស័យអាទិភាពសំដៅទ្រទ្រង់ចីរភាពកំណើន និងបង្កើនផលិតភាពសេដ្ឋកិច្ច និង (៤) ត្រូវប្រើប្រាស់ឥណទានទាំងនេះប្រកបដោយតម្លាភាព និងមានប្រសិទ្ធភាពខ្ពស់បំផុត។

យុទ្ធសាស្ត្រនេះបានកំណត់គោលដៅ និងគោលការរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងបំណុលសាធារណៈរយៈពេល៨ ឆ្នាំ (២០១១-២០១៨) អនុលោមតាមបរិការណ៍នៃក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ គោលនយោបាយថវិកា គោលនយោបាយរូបិយវត្ថុ ស្ថានភាពបំណុលបច្ចុប្បន្ន និងផែនការ តម្រូវការហិរញ្ញប្បទាន ដោយត្រូវរក្សាហានិភ័យនិងបន្ទុកសេវាបំណុលឱ្យនៅកម្រិតអប្បបរមា។ **ឯកសារយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១១-២០១៨** នេះ គឺជាគោលនយោបាយរយៈពេលមធ្យមនិងវែងរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងបំណុលសាធារណៈ និងជាក្របខ័ណ្ឌមួយគ្រប់ជ្រុងជ្រោយ ដែលជាមូលដ្ឋានសម្រាប់គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ធ្វើការសម្រេចចិត្តពាក់ព័ន្ធនឹងការស្វែងរកទុនហិរញ្ញវត្ថុបំពេញតម្រូវការហិរញ្ញប្បទានលើវិស័យអាទិភាពដើម្បីបម្រើឱ្យគោលនយោបាយអភិវឌ្ឍន៍ជាតិប្រកបដោយភាពជឿទុកចិត្ត និងអាចប៉ាន់ប្រមាណបាន ជាពិសេស ការព្យាករណ៍ជាមុននូវបញ្ហាប្រឈមហានិភ័យ និងបន្ទុកសេវាបំណុល។ ទន្ទឹមនឹងនេះ យុទ្ធសាស្ត្រនេះមានគោលដៅកៀរគរទុនហិរញ្ញវត្ថុ សម្រាប់បំពេញតម្រូវការហិរញ្ញប្បទានចំទិសដៅចំណាយអាទិភាពរបស់រាជរដ្ឋាភិបាល ដោយកម្រិតបន្ទុកសេវាបំណុលរយៈពេលវែង និងហានិភ័យបំណុលទាំងក្នុងរយៈពេលខ្លី មធ្យម និងវែងឱ្យស្ថិតក្នុងកម្រិតអប្បបរមា និងប្រុងប្រយ័ត្នខ្ពស់បំផុត ដើម្បីធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងការទ្រទ្រង់ចីរភាពកំណើននិងការអភិវឌ្ឍសេដ្ឋកិច្ច។

លើសពីនេះទៅទៀត ដើម្បីធានាដល់ការគ្រប់គ្រងបំណុលប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពយុទ្ធ-

សាស្ត្រនេះក៏បានដាក់ចេញនូវវិធានការ សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ២០១១-២០១៨ និងយន្តការ ដើម្បីពង្រឹងការតាមដានត្រួតពិនិត្យហានិភ័យបំណុល ព្រមទាំងយន្តការពង្រឹងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្សថែមទៀតផង៕

## ទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ២០១៣ - ២០២០

តាមទិសដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ដែលបានកំណត់តាំងពីចុងឆ្នាំ២០០៤ នៅពេលដាក់ឱ្យអនុវត្តដំណាក់កាលទី១ នោះគឺនឹងសម្រេចឱ្យបាននូវការលើកកម្ពស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាឱ្យដល់កម្រិតស្តង់ដារអន្តរជាតិ ឬ តំបន់ឱ្យបានត្រឹមឆ្នាំ២០១៥ តាមរយៈយុទ្ធសាស្ត្រ៤ ជំហាន ឬ/និង៤ ដំណាក់កាល។ ប៉ុន្តែ ឆ្លងតាមបទពិសោធន៍នៃការអនុវត្តរយៈកាល៨ ឆ្នាំកន្លងទៅនេះ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះនឹងមិនអាចសម្រេចបានចប់សព្វគ្រប់មុនឆ្នាំ២០២៥ បានទេ។ ដូច្នេះ មានន័យថាការកែទម្រង់នេះនឹងត្រូវការពេលវេលាប្រហែល២១ ឆ្នាំ (២០០៥-២០២៥) ពោលគឺ (១) ៤ឆ្នាំ (២០០៥-២០០៨) សម្រាប់ការសម្រេចបានជាសារវន្តនូវភាពជឿទុកចិត្តបានលើថវិកាដែលជាគោលដៅនៃជំហានទី១ ហើយយុទ្ធសាស្ត្រជាគន្លឹះនោះ គឺការពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល ការគ្រប់គ្រងសាច់ប្រាក់ និងការកែលម្អការអនុវត្តចំណាយ (២) ត្រូវការពេលវេលាប្រមាណ៧ ឆ្នាំ (២០០៩-២០១៥) សម្រាប់ការសម្រេចឱ្យបានជាសារវន្តនូវគណនេយ្យភាពហិរញ្ញវត្ថុ ដែលជាគោលដៅនៃជំហានទី២ ហើយដែលយុទ្ធសាស្ត្រជាគន្លឹះនោះ គឺការដាក់ឱ្យអនុវត្តប្លង់គណនេយ្យ និងមាតិកាថវិកាថ្មី អង្គភាពថវិកា និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ (៣) ត្រូវការពេលវេលាប្រមាណ៦ ឆ្នាំ (២០១៥-២០២០) ដើម្បីសម្រេចឱ្យបានជាសារវន្តនូវការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ដែលជាគោលដៅនៃជំហានទី៣ ហើយដែលយុទ្ធសាស្ត្រជាគន្លឹះនោះ គឺការកែទម្រង់ប្រព័ន្ធថវិកា និង (៤) ត្រូវការពេលវេលាប្រមាណ៥ ឆ្នាំ (២០២១-២០២៥) ដើម្បីសម្រេចឱ្យបានជាសារវន្តនូវគណនេយ្យភាពសមិទ្ធកម្ម ដែលជាគោលដៅនៃជំហានទី៤ ហើយដែលយុទ្ធសាស្ត្រជាគន្លឹះនោះ គឺការអនុវត្តពេញលេញនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយផ្អែកលើសមិទ្ធកម្ម ដែលជាគោលដៅចុងក្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ទស្សនាទានស្តីអំពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា២០១៣-២០២០ ត្រូវបានរាជរដ្ឋាភិបាលប្រកាសដាក់ឱ្យអនុវត្ត តាមរយៈយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ សម្រាប់បន្តអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងនីតិកាលទី ៥ របស់រាជរដ្ឋាភិបាល ជាពិសេស ការកែទម្រង់ប្រព័ន្ធថវិកា ដែលនឹងក្លាយទៅជាស្នូលនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ដណាំក់កាលទី៣ និងទី៤ ក្នុងគោលដៅធានាដល់**ការផ្លាស់ប្តូរជាបណ្តើរៗ**

**នូវប្រព័ន្ធគ្រប់គ្រងថវិកាកម្ពុជាពីការផ្តោតលើធាតុចូល និងមជ្ឈការ ទៅជាការផ្តោតលើលទ្ធផល ឬ សមិទ្ធកម្ម និងវិមជ្ឈការឱ្យបានជោគជ័យតាមការគ្រោងទុកពីឆ្នាំ ២០១៣ ដល់ ឆ្នាំ២០២០** ពោលគឺការកែលម្អទៅលើដំណាក់កាលសំខាន់ទាំងបួននៃវដ្តថវិកា គឺការរៀបចំថវិកា ការអនុម័តថវិកា ការអនុវត្តថវិកា និងការត្រួតពិនិត្យតាមដានវាយតម្លៃលទ្ធផល។ ទន្ទឹមនឹងនេះ ប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល ឬ សមិទ្ធកម្មនេះ អាចអនុវត្តទៅបានសម្រេចតាមគោលដៅ ទាមទារឱ្យមានសមត្ថភាពមន្ត្រី និងស្ថាប័នសមស្រប មានប្រព័ន្ធប្រតិបត្តិការការងារប្រកបដោយភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាព និងជាពិសេសមានប្រព័ន្ធគ្រប់គ្រងត្រួតពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលប្រកបដោយតម្លាភាព គណនេយ្យភាពនិងការទទួលខុសត្រូវច្បាស់លាស់ ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព។

ប្រព័ន្ធថវិកាជាតិឆ្នាំ២០២០ ដែលបានកំណត់នៅក្នុងទិសដៅយុទ្ធសាស្ត្រនេះ គឺជាប្រព័ន្ធថវិកាផ្អែកលើលទ្ធផល ឬ សមិទ្ធកម្ម ដែលទាមទារឱ្យមានរចនាសម្ព័ន្ធគោលនយោបាយ (គោលបំណងគោលនយោបាយ កម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព) ច្បាស់លាស់ និងរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន (កម្រិតដឹកនាំគ្រប់គ្រង និងបច្ចេកទេស) សមស្រប ព្រមទាំងមានការកំណត់សិទ្ធិអំណាច និងការទទួលខុសត្រូវច្បាស់លាស់នៅគ្រប់កម្រិត។ ទន្ទឹមនឹងនេះ ទំនាក់ទំនងនៃការផ្សារភ្ជាប់ថវិកាប្រចាំឆ្នាំទៅនឹងគោលនយោបាយដែលគោលនយោបាយ ទាំងនោះអាចមានច្រើនកម្រិត និងត្រូវបានអនុម័តដោយកម្រិតខុសៗគ្នា ថែមទៀតផងដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំត្រូវអនុម័តដោយអង្គការនីតិបញ្ញត្តិ។ លើសពីនេះទៅទៀត ទិសដៅយុទ្ធសាស្ត្រនេះ បានស្នើឱ្យអនុវត្តទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យបាននូវប្រព័ន្ធមួយដែលមានឯកភាព សង្គតិភាព ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពក្នុងការគ្រប់គ្រងថវិកា និងជាពិសេស ត្រូវគោរពឱ្យបានតាមគោលការណ៍គ្រឹះនៃថវិកាទាំង១១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ តាមក្របខ័ណ្ឌនៃប្រព័ន្ធថវិកាថ្មីនេះ ពិសេស ទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានេះ ក៏បានបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់អំពីភាពចាំបាច់នៃការធានាសង្គតិភាព និងភាពស៊ីសង្វាក់គ្នារវាងការកែទម្រង់ ដែលមានលក្ខណៈជាការកែទម្រង់ប្រព័ន្ធទាំង៣ គឺការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ និងការកែទម្រង់រដ្ឋបាលសាធារណៈ ជាពិសេស ទាមទារឱ្យការកែទម្រង់ទាំង៣នេះ រៀបចំទិសដៅយុទ្ធសាស្ត្រ និងផែនការសកម្មភាពឱ្យប្រទាក់ក្រឡា និងស៊ីសង្វាក់គ្នា ដើម្បីធានាដល់ការគាំទ្រ និងបំពេញឱ្យគ្នាទៅវិញទៅមកប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពទើបអាចធានាការសម្រេចបានជោគជ័យនៃការកែទម្រង់នីមួយៗបាន។ ទិសដៅដ៏ចម្បងនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺ**ការផ្លាស់ប្តូរជាបណ្តើរៗពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**ឬប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើធាតុចូល និងមជ្ឈការ ឆ្ពោះទៅប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឬប្រព័ន្ធ គ្រប់គ្រងថវិកាផ្អែកលើលទ្ធផលឬសមិទ្ធកម្មនិងវិមជ្ឈការ** ដែលមានន័យថា ជាការផ្លាស់ប្ដូរប្រព័ន្ធទាំងមូល និង មានផលប៉ះពាល់ដល់កិច្ចប្រតិបត្តិការងារដល់ការប្រើ-ប្រាស់ និងការគ្រប់គ្រងធនធានមនុស្ស ដល់រចនា-សម្ព័ន្ធគ្រប់គ្រង និងចាត់តាំងស្ថាប័ន និងដល់ការផ្លាស់-ប្ដូរការគ្រប់គ្រង។ ការងារនេះ គឺពិតជាស្មុគស្មាញ និង ត្រូវការពេលវេលា ព្រមទាំងត្រូវការឆន្ទៈទាំងកម្រិត នយោបាយ និងបច្ចេកទេសខ្ពស់ ជាពិសេស លុះត្រាតែ មានការដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការងារ កំណែទម្រង់ប្រកបដោយភាពហ្មត់ចត់ ម៉ឺងម៉ាត់ អំណត់ និងព្យាយាមកម្រិតខ្ពស់ ព្រមទាំងមានទិសដៅ និងយុទ្ធ-សាស្ត្រច្បាស់លាស់ និងយន្តការគ្រប់គ្រង ត្រួតពិនិត្យជា ប្រចាំប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពខ្ពស់ ទើបអាចធានាសម្រេចបានជោគជ័យ។ លើសពីនេះ ទៀត គឺតម្រូវឱ្យមានកិច្ចសហការប្រកបដោយភាពជា ម្ចាស់ ការទទួលខុសត្រូវខ្ពស់ និងសកម្មគ្រប់គ្រងពីគ្រប់ តួអង្គទាំងអស់ ជាពិសេស ត្រូវធានារក្សាឱ្យបាននូវ សង្គតិភាពនិងភាពសុខដុមនីយកម្មរវាងការកែទម្រង់ធំៗ និងសំខាន់ៗទាំង៣ ដែលមានលក្ខណៈជាការកែទម្រង់ ប្រព័ន្ធនោះ **គឺការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ ការកែទម្រង់រដ្ឋបាលសាធារណៈ និងការកែ ទម្រង់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ។** ទិសដៅ យុទ្ធសាស្ត្រនេះ ក៏បានគូសបញ្ជាក់ និងកំណត់ផងដែរ អំពីបញ្ហាប្រឈម និងកត្តាកំណត់ជោគជ័យមួយចំនួន ដូចជា (១) ការបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃ ប្រព័ន្ធ (២) ការបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃ ការតាមដានវាយតម្លៃលទ្ធផល និងសមិទ្ធកម្ម (៣) ការ បង្កើនផលិតភាពការងារ តាមរយៈការបង្កើនសមត្ថភាព មន្ត្រី (៤) ការបង្កើនឆន្ទៈ ការប្ដេជ្ញា ភាពជាម្ចាស់ ភាព សកម្មគ្រប់គ្រង និងការទទួលខុសត្រូវនៅគ្រប់កម្រិត និង (៥) ការបង្កើនកិច្ចសហការ និងសម្របសម្រួល ឱ្យកាន់តែស័ក្តិសិទ្ធនិងមានប្រសិទ្ធភាពរវាងការកែទម្រង់ ធំៗ និងសំខាន់ព្រមទាំងមានចរិតជាការកែទម្រង់ប្រព័ន្ធ ទាំង៣ (ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ និង ការកែទម្រង់រដ្ឋបាល)។

ទស្សនាទាននេះក៏បានទទួលស្គាល់ថា ការកែ ទម្រង់ប្រព័ន្ធថវិកានៅកម្ពុជាបាន និងកំពុងដើរលើផ្លូវ ត្រូវ ហើយស្របទៅនឹងនិន្នាការការកែទម្រង់ជាសកល ព្រមទាំងបាន និងកំពុងផ្ដល់ផ្លែផ្កា និងវឌ្ឍនភាពគួរជា ទីលើកទឹកចិត្ត។ ទន្ទឹមនឹងនេះ វឌ្ឍនភាពនិងបទពិសោ-ធន៍ ដែលទទួលបានកន្លងមកពិតជាបានផ្ដល់នូវទស្សនៈ ចំណេះដឹង និងមូលដ្ឋានដ៏រឹងមាំធ្វើឱ្យរាជរដ្ឋាភិបាល មានជំនឿថា ពិតជាមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ ការបន្តអនុវត្តការកែទម្រង់ប្រព័ន្ធថវិកាប្រកបដោយ ជោគជ័យ ដើម្បីឈានទៅសម្រេចឱ្យបាននូវការផ្លាស់ប្ដូរ ប្រព័ន្ធថវិកាកម្ពុជាទាំងស្រុង ពីប្រព័ន្ធថវិកាតាមបន្ទាត់ មាតិកា និងការគ្រប់គ្រងផ្ដោតលើធាតុចូល ទៅជា ប្រព័ន្ធថវិកាកម្មវិធី និងការគ្រប់គ្រងផ្ដោតលើលទ្ធផល និងសមិទ្ធកម្មជាមួយនឹងវិសហមជ្ឈការ និងវិមជ្ឈការ នៅឆ្នាំ២០២០ ដែលជាមូលដ្ឋានដ៏សំខាន់ចាំបាច់ និង

ថែមទាំងជាកត្តាកំណត់ជោគជ័យនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល៕

## ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

គោលបំណងសំខាន់នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺការផ្លាស់ប្តូរជាបណ្តើរៗពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឬប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើធាតុចូល និងមជ្ឈការទៅប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬ ប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផលឬសមិទ្ធកម្ម និងវិមជ្ឈការ ដែលជាប្រព័ន្ធផ្សារភ្ជាប់ការវិភាជថវិកាទៅនឹងសកម្មភាពជាក់ស្តែងនិងកម្មវិធីច្បាស់លាស់ទៅនឹងគោលបំណង គោលនយោបាយអាទិភាពរបស់ក្រសួង ស្ថាប័ន និងជាពិសេស ទៅនឹងគោលបំណង គោលនយោបាយតាមវិស័យ និងរបៀបវារៈគោលនយោបាយថ្នាក់ជាតិរបស់រាជរដ្ឋាភិបាល ដើម្បីធានាថា ថវិកាពិតជាដើរតួនាទីជាឧបករណ៍នៃគោលនយោបាយរបស់រដ្ឋាភិបាល ប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព។

ដើម្បីឆ្ពោះទៅរកគោលបំណងខាងលើការផ្សារភ្ជាប់ថវិកាទៅនឹងគោលបំណងគោលនយោបាយរបស់រាជរដ្ឋាភិបាល គឺជាជំហានដ៏សំខាន់និងចាំបាច់។ ហេតុនេះហើយបានជាផែនការយុទ្ធសាស្ត្រថវិកាត្រូវបានដាក់ឲ្យអនុវត្តនៅក្នុងឆ្នាំ២០០៧ ដែលគ្រប់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវរៀបចំនៅក្នុងដំណាក់កាលទី១ នៃការរៀបចំថវិកាប្រចាំឆ្នាំ គឺក្នុងចន្លោះខែមេសា និងខែឧសភាដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវចេញសារាចរណែនាំ សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកានេះនៅដើមខែមេសា។ ចំណែកឯ រដ្ឋបាលថ្នាក់ក្រោមជាតិនឹងចាប់ផ្តើមរៀបចំនូវផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួនសម្រាប់ថវិកាឆ្នាំ២០១៦ (សម្រាប់តែថវិការដ្ឋបាលរាជធានី ខេត្ត។ ចំពោះរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ត្រូវរៀបចំនៅពេលក្រោយទៀត)។

ផែនការយុទ្ធសាស្ត្រថវិកា គឺជាផែនការថវិការយៈពេលមធ្យម (រយៈពេលបីឆ្នាំ) ដោយឆ្លុះបញ្ចាំងពីគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន និងកសាងកម្មវិធីឬ/និងយុទ្ធសាស្ត្រអាទិភាព ដើម្បីអនុវត្ត និងការកំណត់សូចនាករនិងគោលដៅសូចនាករ សម្រាប់វាស់វែងការអនុវត្ត។ ផែនការនេះ ទាមទារឲ្យមានការកំណត់ធនធាន ទាំងធនធានចរន្តនិងធនធានមូលធន ដែលត្រូវការ និងប្រើប្រាស់សម្រាប់ឆ្នាំថវិកាដែលកំពុងរៀបចំផែនការយុទ្ធសាស្ត្រ និង២ (ពីរ) ឆ្នាំបន្តបន្ទាប់។

ផែនការយុទ្ធសាស្ត្រថវិកា គឺមានគោលបំណងផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ដើម្បីធានាបាននូវការគ្រប់គ្រង និងប្រើប្រាស់ធនធានសាធារណៈប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព។ ម៉្យាងទៀត ផែនការយុទ្ធសាស្ត្រថវិកាផ្តល់ជាមូលដ្ឋានដល់ការរៀបចំថវិកាកម្មវិធី ហើយក៏ជាឧបករណ៍សម្រាប់ការធ្វើសមាហរណកម្មថវិការវាងថវិកាចរន្ត និងថវិកាមូលធន ទាំងថវិការដ្ឋ និងថវិកាដៃគូអភិវឌ្ឍន៍ ដែលជាគោលដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ផែនការយុទ្ធសាស្ត្រថវិកានឹងត្រូវធ្វើសមាហរណកម្មជាមួយក្របខ័ណ្ឌចំណាយរយៈពេលមធ្យម សម្រាប់ជាឧបករណ៍ផ្សារភ្ជាប់ទៅនឹងគោលនយោបាយនិងសម្រាប់ជាមូលដ្ឋានក្នុងការវិភាជថវិកាប្រចាំឆ្នាំប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព ដោយហេតុថា ក្របខ័ណ្ឌ

ចំណាយរយៈពេលមធ្យម ត្រូវបានរៀបចំឡើងតាមអភិក្រមពីលើចុះក្រោមនៅក្នុងការកំណត់កញ្ចប់ថវិកាទៅតាមវិស័យ ដោយផ្អែកលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងអាទិភាពគោលនយោបាយ រីឯផែនការយុទ្ធសាស្ត្រថវិកាត្រូវបានរៀបចំឡើងតាមអភិក្រមពីក្រោមឡើងលើ ដោយបង្ហាញឲ្យឃើញពីតម្រូវការថវិកាជាក់ស្តែងតាមក្រសួង ស្ថាប័ន និងវិស័យនៅក្នុងការអនុវត្តគោលនយោបាយអាទិភាពតាមវិស័យ។

ដ្យាក្រាមខាងក្រោមនេះនឹងបង្ហាញពីទំនាក់ទំនងរវាងគោលនយោបាយជាតិ និងគោលនយោបាយតាមវិស័យ ក្របខណ្ឌចំណាយរយៈពេលមធ្យម និងថវិកាប្រចាំឆ្នាំ និងបង្ហាញពីទំនាក់ទំនងរវាងរចនាសម្ព័ន្ធគ្រប់គ្រងរចនាសម្ព័ន្ធគោលនយោបាយ និងសិទ្ធិអំណាច៕



## មាតិកាថវិកាថ្មី

បន្ទាប់ពីទទួលបានជោគជ័យនៅក្នុងការអនុវត្តដំណាក់កាលទី១ ការបង្កើនភាពជឿទុកចិត្តបាននៃថវិកាដែលបានធ្វើឱ្យចំណូលកើនឡើងជាលំដាប់ ជួយឱ្យការអនុវត្តចំណាយកាន់តែរលូន ព្រមទាំងបានលុបបំបាត់ទាំងស្រុងនូវកង្វះសាច់ប្រាក់ និងបំណុលដែលធ្លាប់តែរាំរ៉ៃ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តជាផ្លូវការនូវកម្មវិធីការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ គឺការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុនៅចុងឆ្នាំ២០០៨។ ការរៀបចំក្របខ័ណ្ឌមាតិកាថវិកាមានលក្ខណៈគ្រប់ជ្រុងជ្រោយ សម្រាប់បម្រើឱ្យការកត់ត្រា និងរបាយការណ៍ហិរញ្ញវត្ថុ គឺជាសកម្មភាពគន្លឹះមួយនៅក្នុងដំណាក់កាលទី២ ដើម្បីបង្កើតម្ចាស់ភាព និងគណនេយ្យភាពហិរញ្ញវត្ថុ។

មាតិកាថវិកា គឺជាប្រព័ន្ធនៃចំណាត់ថ្នាក់ និងលេខកូដ ដែលប្រើប្រាស់សម្រាប់កត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុទាំង ចំណូលនិងចំណាយ។ ដើម្បីធានាការកត់ត្រា និងរបាយការណ៍ហិរញ្ញវត្ថុមានលក្ខណៈគ្រប់ជ្រុងជ្រោយ មាតិកាថវិកាថ្មីត្រូវបានបង្កើតជា៧ ចំណាត់ថ្នាក់គឺ÷

១. ចំណាត់ថ្នាក់ភូមិសាស្ត្រ គឺជាការបញ្ជាក់អំពីទីតាំងភូមិសាស្ត្រ (រាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ ឃុំ/សង្កាត់) ដើម្បីកត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុ។

២. ចំណាត់ថ្នាក់មុខងារ គឺជាការបញ្ជាក់អំពីគោលបំណងនៃប្រតិបត្តិការហិរញ្ញវត្ថុ និងបញ្ជាក់អំពីគោលបំណងនៃការចំណាយតាមវិស័យ និងអនុវិស័យ។ ព័ត៌មាននេះមានសារៈសំខាន់ណាស់ សម្រាប់ការវិភាគការប្រៀបធៀប និងការរៀបចំគោលនយោបាយ ជាពិសេស ការរៀបចំគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងការវិភាគជធនធាន។ ចំណាត់ថ្នាក់នេះត្រូវបានរៀបចំ ដោយអនុលោមតាមស្តង់ដារមុខងារ COFOG (Classification of the Functions of the Government) របស់អង្គការសហប្រជាជាតិ។

៣. ចំណាត់ថ្នាក់អង្គភាពប្រតិបត្តិ និងរដ្ឋបាល គឺជាការបញ្ជាក់អំពីស្ថាប័នដែលទទួលខុសត្រូវ ដើម្បីកត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុ។

៤. ចំណាត់ថ្នាក់កម្មវិធី គឺជាការបញ្ជាក់អំពីកម្មវិធីដើម្បីកត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុ។ ចំណាត់ថ្នាក់កម្មវិធីកំណត់ថាតើ កម្មវិធី/អនុកម្មវិធី ឬចង្កោមសកម្មភាពណាដែលបង្កើតចំណូល ឬ/និងត្រូវការចំណាយ។

៥. ចំណាត់ថ្នាក់សេដ្ឋកិច្ចត្រូវបានប្រើប្រាស់សម្រាប់កំណត់កម្មវត្ថុនៃចំណាយ ឬ ចំណូល ដើម្បីកត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុ (ក្រុម ប្រភេទ ជំពូក គណនី ឬ អនុគណនី ដែលចំណូលឬ/និងចំណាយបានកើតឡើង)។

៦. ចំណាត់ថ្នាក់មូលនិធិ គឺជាការបញ្ជាក់អំពីប្រភពផ្តល់ហិរញ្ញប្បទានសម្រាប់អនុវត្តកម្មវិធី ឬគម្រោង។

៧. ចំណាត់ថ្នាក់គម្រោង គឺការបញ្ជាក់អំពីការវិនិយោគសាធារណៈក្នុងវិស័យណាមួយ ដោយមានប្រភពហិរញ្ញប្បទានច្បាស់លាស់ និងក្នុងរយៈពេលកំណត់។

ការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់ទាំង៧ នេះ គឺពិតជាការផ្លាស់ប្តូរដ៏ធំមួយនៅក្នុងមាតិកាថវិកាបច្ចុប្បន្ន ដែលមានតែ២ ចំណាត់ថ្នាក់ គឺចំណាត់ថ្នាក់រដ្ឋបាល និង

សេដ្ឋកិច្ច។ ចំណាត់ថ្នាក់នីមួយៗនៃរចនាសម្ព័ន្ធមាតិកាថ្មីនេះ មានលក្ខណៈលម្អិត ច្បាស់លាស់ គ្រប់ជ្រុងជ្រោយ និងមានសង្គតិភាព ហើយឆ្លើយតបទៅនឹងតម្រូវការក្នុងការរៀបចំរបាយការណ៍គណនេយ្យនិងហិរញ្ញវត្ថុ និងការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា (FMIS) ដែលត្រូវដាក់ឱ្យអនុវត្តនៅក្នុងខែកក្កដា ឆ្នាំ២០១៥ នេះ។ ជាពិសេស រចនាសម្ព័ន្ធនៃចំណាត់ថ្នាក់ថ្មីនេះ ធានាបានផងដែរនូវសុខដុមនីយកម្មរវាងចំណាត់ថ្នាក់សេដ្ឋកិច្ច និងប្លង់គណនី ដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យមានសង្គតិភាពទៅនឹងស្តង់ដារអន្តរជាតិ។ ជារួម មាតិកាថវិកាថ្មីនឹងផ្តល់អត្ថប្រយោជន៍សំខាន់ៗដូចជា៖ (១) ធ្វើឱ្យការកត់ត្រា និងរបាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ (២) ធ្វើឱ្យការវិភាគការព្យាករណ៍ និងការប្រៀបធៀបមានលក្ខណៈងាយស្រួល និងសុក្រឹត (៣) ធ្វើឱ្យការរៀបចំថវិកា ការត្រួតពិនិត្យតាមដាន និងការគ្រប់គ្រងការអនុវត្តថវិកាមានលក្ខណៈងាយស្រួល និង (៤) ធ្វើឱ្យប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូលកាន់តែមានតម្លាភាព និងគណនេយ្យភាព។

គោលការណ៍ណែនាំស្តីពីការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មីត្រូវបានរៀបចំនិងកែលម្អជាបន្តបន្ទាប់ និងបានកែសម្រួលចុងក្រោយនៅខែធ្នូ ឆ្នាំ២០១៤ ដោយអគ្គនាយកដ្ឋានថវិកា។ ក្នុងគោលការណ៍នេះ ក៏បានកំណត់ពីផែនការនៃការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មីផងដែរ។ គោលដៅក្នុងឆ្នាំ២០១៥ គឺដាក់ឱ្យអនុវត្តពេញលេញចំណាត់ថ្នាក់សេដ្ឋកិច្ចមាន៥ កម្រិត គឺថ្នាក់ ប្រភេទ ជំពូក គណនី អនុគណនី និងដាក់ឱ្យអនុវត្តមួយផ្នែកនៃចំណាត់៦ ទៀតដូចជា ចំណាត់ថ្នាក់ភូមិសាស្ត្រមាន២ កម្រិត គឺរាជធានី/ខេត្ត និងក្រុង/ស្រុក/ខណ្ឌ ចំណាត់ថ្នាក់អង្គភាពប្រតិបត្តិ និងរដ្ឋបាលមាន៣ កម្រិតនៅថ្នាក់ជាតិ គឺក្រសួង អគ្គនាយដ្ឋាន និងនាយដ្ឋាន និង១ កម្រិតនៅថ្នាក់ក្រោមជាតិ គឺសាលារាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ/ឃុំ/សង្កាត់ ចំណាត់ថ្នាក់មុខងារមាន១ កម្រិត គឺមុខងារចំណាត់កម្មវិធីមាន២ កម្រិត គឺកម្មវិធី និងអនុកម្មវិធី ចំណាត់ថ្នាក់មូលនិធិមាន២ កម្រិត គឺប្រភេទ និងប្រភព និងចំណាត់ថ្នាក់គម្រោងមាន៣ កម្រិត គឺគម្រោងសមាសភាគ និងអនុសមាសភាគ។ គោលការណ៍ណែនាំស្តីពីការដាក់ឱ្យអនុវត្តមាតិកថវិកាថ្មីគ្រោងពិនិត្យនិងកែលម្អនៅឆ្នាំ២០១៦/២០១៧ បន្ទាប់ពីដាក់ឱ្យអនុវត្តមួយរយៈពេល និងគ្រោងនឹងដាក់ឱ្យអនុវត្តពេញលេញទាំង៧ ចំណាត់ថ្នាក់នៅឆ្នាំ២០១៨៕

## ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ




*ប្រព័ន្ធថវិកាជាតិឆ្នាំ២០២០ ដែលបានកំណត់ខាងលើ គឺជាប្រព័ន្ធថវិកាជាតិផ្អែកលើលទ្ធផល ឬ សមិទ្ធកម្មដែលទាមទារឱ្យមានរចនាសម្ព័ន្ធគោលនយោបាយ (គោលនយោបាយ កម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព) ច្បាស់លាស់ និងរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន (កម្រិតដឹកនាំ គ្រប់គ្រង និងបច្ចេកទេស) សមស្រប ព្រមទាំងមានការកំណត់សិទ្ធិអំណាច និងទទួលខុសត្រូវច្បាស់លាស់ នៅគ្រប់កម្រិត ទើបអាចអនុវត្តទៅប្រកបដោយភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាពបាន។*

## ថវិកាកម្មវិធី

ដើម្បីឈានទៅសម្រេចបានជាស្តង់ដារអន្តរជាតិ រាជរដ្ឋាភិបាលកម្ពុជាមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការបានកំណត់ និងដាក់ចេញនូវទិសដៅយុទ្ធសាស្ត្រការកែទម្រង់ប្រព័ន្ធថវិកា ២០១៣-២០២០ ដែលជាវិថីនៃការកែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈសម្រាប់ធានាដល់កាផ្លាស់ប្តូរជាបណ្តើរៗនូវប្រព័ន្ធគ្រប់គ្រងថវិកាពីការផ្តោតលើធាតុចូលនិងមជ្ឈការ ទៅជាការផ្តោតលើលទ្ធផលឬសមិទ្ធកម្ម និងវិមជ្ឈការឱ្យបានជោគជ័យតាមការគ្រោងទុក។ ពោលគឺ ការកែលម្អទៅលើដំណាក់កាលសំខាន់ទាំងបួននៃវដ្តថវិកា គឺការរៀបចំថវិកា ការអនុម័តថវិកា ការអនុវត្តថវិកា និងការត្រួតពិនិត្យ តាមដានវាយតម្លៃលទ្ធផល។ គួរបញ្ជាក់ផងដែរថា **ថវិកាកម្មវិធី** គឺជាយុទ្ធសាស្ត្រគន្លឹះ ដែលបានរំលេចនៅក្នុងទិសដៅយុទ្ធសាស្ត្រការកែទម្រង់ប្រព័ន្ធថវិកា ២០១៣-២០២០ និងបានចាត់ជាកម្មវត្ថុដ៏សំខាន់មួយនៃការកែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

**ថវិកាកម្មវិធី** (Program Budgeting) គឺជាប្រព័ន្ធថវិកា ដែលផ្តោតលើលទ្ធផលក្នុងឆ្នាំឬលទ្ធផលចុងក្រោយដោយមិនផ្តោតតែលើធាតុចូលទេ តែវាផ្អែកលើកម្មវិធីដែលបានរៀបចំឡើង និងគណនេយ្យភាពចំពោះលទ្ធផលដើម្បីសម្រេចគោលបំណង គោលនយោបាយរបស់រដ្ឋាភិបាល និងក្រសួង ស្ថាប័ន។ ក្នុងន័យនេះ **ថវិកាកម្មវិធី** ត្រូវមានសូចនាករសមិទ្ធកម្មតាមដាន វាស់វែង និងរៀបចំរបាយការណ៍លទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយទៅតាមកម្មវិធីនិងអនុកម្មវិធីនីមួយៗ។ **ថវិកាកម្មវិធី** ត្រូវកំណត់ឲ្យបានច្បាស់នូវតម្លៃធាតុចូល ដែលមានចំណាយចរន្ត និងចំណាយមូលធនចាំបាច់សម្រាប់ការអនុវត្តចង្កោមសកម្មភាព កម្មវិធី និងអនុកម្មវិធី។ ជាពិសេស **ថវិកាកម្មវិធី**នឹងជួយពង្រឹងដល់ការផ្សារភ្ជាប់រវាងថវិកាទៅនឹងគោលនយោបាយតាមវិស័យ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល (ជាក់ស្តែង គឺការរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងស្ថាប័ន) ព្រោះថា **ថវិកា**ជាឧបករណ៍គោលនយោបាលរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស គោលនយោបាយហិរញ្ញវត្ថុសាធារណៈរួមមាន គោលនយោបាយចំណូល និងគោលនយោបាយចំណាយ។

ដោយមើលឃើញអត្ថប្រយោជន៍ទាំងនេះ រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមអនុវត្តថវិកាកម្មវិធី (PB) នៅឆ្នាំ២០០៧ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមរយៈការដាក់ឲ្យអនុវត្តសាកល្បងថវិកាកម្មវិធីនៅក្រសួងចំនួន០៧ គឺក្រសួងយុត្តិធម៌, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសុខាភិបាល និងក្រសួងកិច្ចការនារី។ ដោយឡែក ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមអនុវត្តសាកល្បងថវិកាកម្មវិធីនេះនៅឆ្នាំ២០០៨។ ដើម្បីកំណត់ទិសដៅច្បាស់លាស់អំពីការកែទម្រង់ថវិកា ដែលជាផ្នែកសំខាន់មួយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺនៅឆ្នាំ២០១១ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំវាយតម្លៃលើការអនុវត្តសាកល្បងថវិកា

កម្មវិធីរបស់ក្រសួងទាំង០៨ ដែលបានអនុវត្តរយៈពេល ០៥ ឆ្នាំកន្លងមក។ ជាលទ្ធផលនៃការវាយតម្លៃ ការរៀបចំថវិកាពីមួយឆ្នាំទៅមួយឆ្នាំកាន់តែមានលក្ខណៈច្បាស់លាស់ ជាក់ស្តែង សុក្រឹត តម្លាភាព និងគណនេយ្យភាពជាងមុន ទោះបីបច្ចុប្បន្នថវិកាកម្មវិធីមានប្រមាណត្រឹម ៣២% នៃថវិកាសរុបរបស់ក្រសួងទាំង០៨ យ៉ាងណាក៏ដោយ។ ជោគជ័យនៃការអនុវត្តសាកល្បងថវិកាកម្មវិធីនេះ បានជំរុញឲ្យរាជរដ្ឋាភិបាលសម្រេចដាក់ឲ្យក្រសួងចំនួន១០ អនុវត្តថវិកាកម្មវិធីពេញលេញចាប់ពីឆ្នាំ២០១៥ តទៅ ក្នុងនោះរួមមានក្រសួងទាំង០៨ ដែលបានអនុវត្តសាកល្បងថវិកាកម្មវិធី និងក្រសួងសាធារណៈការនិងដឹកជញ្ជូន ព្រមទាំងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដោយឡែក ក្រសួង ស្ថាប័នដទៃទៀតនឹងត្រូវដាក់ឲ្យអនុវត្តថវិកាកម្មវិធីពេញលេញជាបន្តបន្ទាប់ចាប់ពីឆ្នាំ ២០១៦ តទៅ ដើម្បីសម្រេចគោលដៅនៃការដាក់ឲ្យគ្រប់ក្រសួង ស្ថាប័នទាំងអស់អនុវត្តថវិកាកម្មវិធីពេញ-លេញក្នុងឆ្នាំ២០២០ ស្របតាមទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា២០១៣-២០២០។

ដើម្បីសម្រេចបាននូវក្របខ័ណ្ឌកម្មវិធីការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាទិសដៅយុទ្ធ-សាស្ត្រការកែទម្រង់ប្រព័ន្ធថវិកា ២០១៣-២០២០ ដោយគិតត្រឹមឆ្នាំ២០១៥ ដល់ឆ្នាំ២០២០ ជាគោលដៅ គឺត្រូវបន្តពង្រឹងការអនុវត្តនិងជំរុញឱ្យក្រសួង ស្ថាប័នស្ម័គ្រចិត្តចូលរួមអនុវត្ត**ថវិកាកម្មវិធី**ពេញលេញ ហើយនឹងធ្វើការត្រួតពិនិត្យឡើងវិញនៅក្នុងឆ្នាំ២០១៧ ឬ ២០១៨ ដើម្បីអនុញ្ញាតឱ្យមានកែលម្អបន្ថែម និងត្រៀមលក្ខណៈសម្រាប់ការអនុវត្តពេញលេញនូវប្រព័ន្ធថវិកាកម្មវិធីនៅត្រឹមឆ្នាំ២០២០។ ជាពិសេស នឹងនាំឆ្ពោះទៅរកការគ្រប់គ្រងថវិកាផ្អែកលើលទ្ធផលនិងសមិទ្ធកម្ម ពោលគឺការផ្លាស់ប្តូរប្រព័ន្ធថវិកាទាំងស្រុងពីថវិកាផ្អែកលើបន្ទាត់មាតិកា ទៅជាប្រព័ន្ធថវិកាកម្មវិធីនិងការគ្រប់គ្រងដោយផ្អែកលើលទ្ធផលនិងសមិទ្ធកម្មចាប់ពីឆ្នាំ២០២០ តទៅ។ មានន័យថា វាត្រូវការពេលវេលាប្រមាណ៦ ឆ្នាំទៅមុខទៀត ដើម្បីសម្រេចឱ្យបានជាសារវន្តនូវការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ដែលជាគោលដៅនៃដំណាក់កាលទី៣ ហើយដែលយុទ្ធសាស្ត្រជាគន្លឹះនោះគឺការបន្តពង្រឹង និងពង្រីកការអនុវត្ត**ថវិកាកម្មវិធី** ដែលជាការស្នូលក្នុងការកែទម្រង់ប្រព័ន្ធថវិកា។

## ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជាអ្វី?

ប្រព័ន្ធ FMIS គឺជាការធ្វើសមាហរណកម្មស្វ័យប្រវត្តិកម្មនូវដំណើរការការងារការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបច្ចុប្បន្នកំពុងប្រតិបត្តិដោយដៃនឹងត្រូវផ្លាស់ប្តូរទៅអនុវត្តតាមកម្មវិធីកុំព្យូទ័រ និងឧបករណ៍កុំព្យូទ័រវិញ ដោយរាប់បញ្ចូលទាំងធនធានមនុស្ស អង្គភាព និងការគ្រប់គ្រងការផ្លាស់ប្តូរទាំងនេះបង្កើតឱ្យមាននីតិ-វិធីអនុវត្តការងារថ្មី។ ប្រព័ន្ធ FMIS គឺជាមូលដ្ឋានដ៏សំខាន់ និងចាំបាច់សម្រាប់ភាពជោគជ័យនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP)ដែលកំពុងតែបោះជំហានទៅមុខ ជាពិសេស នៅពេលដែលប្រព័ន្ធនេះត្រូវបានដាក់ឱ្យប្រើប្រាស់នាពាក់កណ្តាលខែ

កក្កដា ឆ្នាំ២០១៥ សម្រាប់តែអគ្គនាយកដ្ឋាន/នាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនៅគ្រប់រតនាគាររាជធានី ខេត្ត។ គោលដៅចម្បងនៃការអនុវត្តគម្រោងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) គឺដើម្បីគាំទ្រ ជំរុញ និងពន្លឿនសកម្មភាពទូទៅរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) នៅគ្រប់ដំណាក់កាលដោយបង្កើនបាននូវគណនេយ្យភាព ប្រសិទ្ធភាព ភាពស័ក្តិសិទ្ធ និងការធ្វើទំនើបភាវូបនីយកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា តាមរយៈផ្តល់នូវព័ត៌មានចំណូលចំណាយថវិកាគ្រប់ជ្រុងជ្រោយ និងទាន់ពេលវេលា។ ដោយឡែកសម្រាប់រយៈពេលវែង ប្រព័ន្ធ FMIS នឹងផ្តល់នូវការប្រើស្វ័យប្រវត្តិកម្មលើការធ្វើផែនការថវិកា ការធ្វើនីយកម្មថវិកា និងការអនុវត្តថវិកា ដែលជួយឱ្យប្រព័ន្ធគ្រប់គ្រងកាន់តែមានប្រសិទ្ធភាពខ្ពស់។ មានន័យថាក្រសួងនឹងចាប់ផ្តើមទទួលបាននូវឱកាសពិតក្នុងការផ្លាស់ប្តូរទៅកាន់ការរៀបចំរបាយការណ៍ និងដំណើរការប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈឱ្យកាន់តែមានភាពជឿជាក់ រហ័សទាន់ពេល និងល្អប្រសើរ។ គួរគូសបញ្ជាក់ផងដែរថា ប្រព័ន្ធ FMIS ក៏នឹងមិនមើលរំលងទៅដល់ការដាក់ឱ្យក្រសួង ស្ថាប័នដទៃអនុវត្តនោះទេ យ៉ាងណាមិញ ក្រសួង ស្ថាប័នទាំងនោះនឹងត្រូវមានភារៈកិច្ចរួមចំណែកអនុវត្តនៅពេលដែលប្រព័ន្ធនេះត្រូវបានដាក់ឱ្យអនុវត្តពេញលេញ និងជោគជ័យនៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន។

ដោយឃើញពីភាពចាំបាច់ តម្រូវការ និងអត្ថប្រយោជន៍ ប្រព័ន្ធ FMIS នឹងត្រូវដាក់ឱ្យអនុវត្តជាបណ្តើរៗ នាខែកក្កដា ឆ្នាំ២០១៥ ខាងមុខ ដែលវានឹងជួយពង្រឹងដល់ការអនុវត្តថវិកា តាមរយៈការចំណាយដោយស្វ័យប្រវត្តិតាមប្រព័ន្ធកុំព្យូទ័រ ការទទួលចំណូល ការប្រមូលចំណូល និងប្រាក់បញ្ញើសម្រាប់ចំណូលមិនមែនសារពើពន្ធ ព្រមទាំងភ្ជាប់ជាមួយប្រព័ន្ធចំណូលពន្ធដារ ពន្ធគយ និងគ្រប់គ្រងបំណុលគណនេយ្យ និងរបាយការណ៍នៅរតនាគារកណ្តាល និងបណ្តារតនាគារខេត្ត ព្រមទាំងអាចផ្តល់នូវតម្លាភាពក្នុងការទទួលនូវរាល់ព័ត៌មានហិរញ្ញវត្ថុតាម online។ មិនត្រឹមតែប៉ុណ្ណោះប្រព័ន្ធ FMIS គឺជាកាលានុវត្តភាព សម្រាប់អនុវត្តនូវនីតិវិធីដ៏ល្អបំផុតមួយស្របតាមបទដ្ឋានអន្តរជាតិនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋាភិបាល។ ជាងនេះទៅទៀត វានឹងធ្វើឱ្យនីតិវិធីអនុវត្តការងាររតនាគារ និងថវិកាមានលក្ខណៈស្តង់ដារ ហើយនឹងផ្តល់នូវព័ត៌មានរតនាគារ និងថវិកាប្រកបដោយសុក្រឹតភាព និងទាន់ពេលវេលា ព្រមទាំងជួយពង្រឹងការវាស់វែងលើសមិទ្ធផលការងារផងដែរ ។ ជាពិសេស ប្រព័ន្ធនេះនឹងធ្វើឱ្យយន្តការត្រួតពិនិត្យហិរញ្ញវត្ថុមានលក្ខណៈស្តង់ដារ និងឈានទៅរកការកែលម្អការគ្រប់គ្រងហិរញ្ញវត្ថុ ស្របពេលដែលការធ្វើផែនការនិងគ្រប់គ្រងធនធានហិរញ្ញវត្ថុប្រកបដោយភាពស័ក្តិសិទ្ធ និងឈានឆ្ពោះទៅរកការធ្វើឱ្យប្រសើរឡើងនូវទំនើបភាវូបនីយកម្មនៃការគ្រប់គ្រងថវិកាជាតិរួមមានការរៀបចំថវិកា ការអនុវត្តថវិកា ការធ្វើរបាយករណ៍ និងកែលម្អគណនេយ្យភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទន្ទឹមនេះ ប្រព័ន្ធ FMIS នឹងជួយពង្រឹងការកែលម្អនូវ

តម្លាភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងបង្កើនសុវត្ថិភាពចំពោះព័ត៌មានហិរញ្ញវត្ថុរួមទាំងការទ្រទ្រង់អភិបាលកិច្ចល្អ ដែលជាចំណែកក្នុងការកាត់បន្ថយភាពក្រីក្រជាដើម។

ជាក់ស្តែង អំឡុងពេលនៃកិច្ចដំណើការរៀបចំប្រព័ន្ធ FMIS យើងក៏មិនអាចចៀសផុតពីបញ្ហាប្រឈម និង ឧបសគ្គមួយចំនួនដែលអគ្គនាយកដ្ឋាន/នាយកដ្ឋានផ្ទៃក្នុងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានជួបប្រទះ នេះមិនទាន់រាប់បញ្ចូលក្រសួង ស្ថាប័នដទៃ ដែលមិនទាន់បានរៀបចំ។ ជាឧបសគ្គ និងបញ្ហាប្រឈមរួម គឺការផ្លាស់ការអនុវត្តការងារ ដែលធ្លាប់ធ្វើបច្ចុប្បន្នឈានទៅរកការអនុវត្តតាមនីតិវិធី និងអភិក្រមថ្មីមួយនាពេលអនាគត នេះមិនមែនមានន័យថា ប្រព័ន្ធ FMIS នឹងកាត់បន្ថយចំនួនបុគ្គលិក/មន្ត្រី ប៉ុន្តែផ្ទុយទៅវិញ គឺដើម្បីបង្កើនប្រសិទ្ធភាពការងារ ដើម្បីឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការនៃអនុវត្តស្តង់ដារការងារនិងស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា។ លទ្ធផលទាំងអស់នេះ នឹងផ្តល់នូវមូលដ្ឋានដ៏រឹងមាំមួយសម្រាប់ជួយពន្លឿន និងទ្រទ្រង់ដល់កម្មវិធីកែទម្រង់ PFMRP ដែលរួមមានការអនុវត្ត ថវិកាកម្មវិធី ការប្រព្រឹត្តិទៅនៃអង្គភាពថវិកា និងការកែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា។ ជារួម អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាននឹងកំពុងផ្តោតយកចិត្តទុកដាក់ជាអាទិភាពសម្រាប់ដំណាក់កាលទី២ នេះ គឺការដាក់ឱ្យអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយឆន្ទៈក្នុងការឈានទៅរកជោគជ័យនៃគណនេយ្យភាពហិរញ្ញវត្ថុ សម្រាប់រដ្ឋាភិបាលកម្ពុជា។

ជាទិសដៅ និងយុទ្ធសាស្រ្ត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ចេញការអនុវត្តជាពីរដំណាក់កាល ដែលការអនុវត្តក្នុងដំណាក់កាលទី១ របស់ប្រព័ន្ធ FMIS ផ្តោតសំខាន់តែលើមុខងាររតនាគារ ដោយអនុញ្ញាតឱ្យអនុវត្តប្រតិបត្តិការថវិកា និងការធានាចំណាយ។ វិសាលភាពនៃផែនការសកម្មភាពនេះនឹងត្រូវពាក់ព័ន្ធជាមួយអគ្គនាយកដ្ឋានគន្លឹះរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកដ្ឋានថវិកា អគ្គនាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងអគ្គាធិការដ្ឋាន) និងរតនាគាររាជធានី ខេត្តទាំង២៤។ សម្រាប់ដំណាក់កាលទី២ នឹងរំពឹងថា តាមរយៈភាពជោគជ័យ និងអត្ថប្រយោជន៍ដែល FMIS នឹងបានផ្តល់នាពេលអនាគត ប្រព័ន្ធ FMIS នឹងប្រែក្លាយទៅជាប្រព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយដ៏ពេញលេញ និងចាំបាច់។ គោលបំណងសម្រាប់ពេលអនាគត គឺដើម្បីរួមបញ្ចូលការពង្រីកនូវវិសាលភាពមុខងារតាមរយៈមុខងារបន្ថែមដូចជាផែនការ ថវិកា និងការរៀបចំថវិកា កិច្ចលទ្ធកម្ម (មុខងារបញ្ជា ទិញទាំងមូល) ទ្រព្យសកម្ម និងសន្និធិ។ ទោះបីជាមុខងារទាំងនេះមិនទាន់ត្រូវបានអនុវត្ត ឬ រៀបចំដំឡើងនៅក្នុងដំណាក់កាលទី១ នេះ (គោលបំណងបច្ចុប្បន្ន) ក៏ដោយ ក៏មុខងារទាំងនេះមានសារៈសំខាន់សម្រាប់គោលដៅទៅថ្ងៃអនាគតសម្រាប់ក្រសួងសេដ្ឋកិច្ច

និងហិរញ្ញវត្ថុ ដែលមុខងារទាំងអស់នឹងត្រូវដាក់ឲ្យអនុវត្តដូចដែលបានគ្រោងទុក។

ជារួម ចាប់ពីខែ កក្កដា ឆ្នាំ២០១៥ តទៅ គឺជាពេលដំបូង ដែលព័ត៌មានស្តីពីការអនុវត្តថវិកានឹងត្រូវផលិតចេញមក ដើម្បីជាសក្ខីភាពនៃការខិតខំប្រឹងប្រែង និងប្តេជ្ញាចិត្តរួមគ្នារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជារាជរដ្ឋាភិបាល។ ជាពិសេស កម្ពុជានឹងចាប់ផ្តើមមានព័ត៌មាន និងទិន្នន័យឯកភាពមួយសម្រាប់ការគ្រប់គ្រង និងអនុវត្តថវិកា ដែលផលិតចេញនូវរបាយការណ៍តាមបែប IPSAS Cash Basis សម្រាប់ជាតិទាំងមូល និងដើម្បីជាធាតុចូលល្អប្រសើរជាងមុនក្នុងការផ្លាស់ប្តូរទិន្នន័យជាមួយប្រទេសនានាក្នុងតំបន់ ក៏ដូចជាបម្រើឱ្យការចូលរួមក្នុងសមាហរណកម្មអាស៊ានក្នុងពេលដ៏ខ្លីខាងមុខនេះដែរ៕

# ក្រុមការងាររៀបចំព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

| | | |
|---|---|---|
| ១. | បណ្ឌិត **សុខ សារាវុឌ្ឍ** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| ២. | បណ្ឌិត **ហ៊ែល ចំរើន** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| ៣. | លោក **មាស សុខសេនសាន** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| ៤. | លោក **ម៉ី វឌ្ឍសុខា** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| ៥. | លោក **យ៉េត វីណែល** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| ៦. | លោក **អ៊ុំ យុទ្ធី** | មន្ត្រីជំនាញជាន់ខ្ពស់ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| ៧. | លោក **ហៀង សុយ៉ារ៉ូ** | មន្ត្រីជំនាញ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| ៨. | លោក **លី ឌ៉ុង** | មន្ត្រីជំនាញ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| ៩. | លោក **អ៊ុច សោភ័ណ** | មន្ត្រីជំនាញ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| ១០. | លោក **ឆៀង សុខតីរម្យ** | មន្ត្រីជំនាញ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| ១១. | លោក **យន ម៉ាលីមនេង** | មន្ត្រីជំនាញ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |

**អាសយដ្ឋានទំនាក់ទំនង**
ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានី ភ្នំពេញ កម្ពុជា
(៨៥៥)-២៣ ៤៣០ ៧៩១ Tel: ០១២ ៧៥៧ ១៥៨
E-mail: admin@pfm.gov.kh